01671508

D270/7

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 20-May-2021, 09:17
CMS/CFO: Sann Rada

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖** ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០២១

ភាសា ៖ អង់គ្លេស និងខ្មែរ

ចំណាត់ថ្នាក់ឯកសារ ៖ សាធារណៈ

# សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា៖**

ជា លាង

Brenda J. HOLLIS

**មេធាវីការពារក្តី មាស មុត**

អាង ឧត្តម

Michael G. KARNAVAS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
**និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖**

ហុង គឹមសួន
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ

Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ គឺជាង១៦ខែ បន្ទាប់ពីសវនការនៅចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿងនេះបានបញ្ចប់ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួន (“សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣”)[1] លើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី មាស មុត (“មេធាវីការពារក្តី”) និងសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ។ អត្ថបទ និងខ្លឹមសារនៃទឡ្ហីករណ៍ពាក់ព័ន្ធ នៅក្នុងផ្នែកសំខាន់ៗ គឺដូចគ្នានឹងសេចក្តីពិចារណាកន្លងមក នៅក្នុងសំណុំរឿង ០០៤/២ (“សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២”) ដែលបានចេញកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អស់ពេលជាង១៥ខែ មុនសេចក្តីពិចារណាក្នុងសំណុំរឿង ០០៣[2]។ ជាពិសេស គួរកត់សម្គាល់ថា អង្គបុរេជំនុំជម្រះ មិនបានចំណាយពេលដើម្បីពិភាក្សាលម្អិតអំពីទីតាំងឧក្រិដ្ឋកម្ម និងបទចោទជាក់លាក់ណាមួយ ដែលបានកើតឡើងក្នុងសំណុំរឿង ០០៣ ឡើយ។

២. នៅពេលដែលសវនាការក្នុងសំណុំរឿង ០០៣ ត្រូវបានធ្វើឡើង នៅថ្ងៃទី២៧ ដល់២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ ច្បាស់ណាស់ថា ជិតដល់ដំណាក់កាលចុងក្រោយទៅហើយ ដែលសេចក្តីពិចារណានោះ ត្រូវបានចេញរួចរាល់ជាបីភាសា នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩[3]។ ការនេះគឺពាក់ព័ន្ធជាមួយការពិភាក្សារបស់យើង ទៅលើទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ដូចដែលយើងនឹងបង្ហាញជូននៅផ្នែកខាងក្រោម។

---

[1] ឯកសារ **D266/27** & **D267/35** *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ* ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ (“សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣”)។

[2] **សំណុំរឿងលេខ ០០៤/២ ឯកសារ D359/24** & **D360/33** *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ* ថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ២០១៩ (“សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២”)

[3] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ ឯកសារជាភាសាអង់គ្លេស (ERN: 01634170-01634444) ឯកសារជាភាសាខ្មែរ (ERN: 01634753-01635147) ឯកសារជាភាសាបារាំង (ERN: 01634445-01634752)។

01671510



៣. សេចក្តីពិចារណាទាំងពីរ ចាប់ផ្តើមពីការពិភាក្សាអំពីវិធានរកសំឡេងមិនបាន ដែលថា “ការស៊ើបអង្កេតដំណើរការទៅមុខ” ដែលសន្និដ្ឋានថា “សំណុំរឿងដំណើរការទៅមុខ”[4]។ ដោយផ្អែកលើមូលដ្ឋាននេះ យើងទទួលការរិះគន់លើការចេញដីកាដំណោះស្រាយដាច់ពីគ្នា ដោយមិនចេញដីកាដំណោះស្រាយរួមគ្នាតែមួយ ដែលត្រូវបានចងដោយវិធានរកសំឡេងមិនបាន ហើយដែល សហចៅក្រមស៊ើបអង្កេតជាតិ ត្រូវចុះហត្ថលេខាលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ យើងសូមកត់សម្គាល់ថា អង្គបុរេជំនុំជម្រះ មិនបានគោរពតាមការសម្រេចរួមគ្នារបស់ខ្លួន ផ្អែកតាមវិធានរកសំឡេងមិនបាន ព្រោះទាំងនៅក្នុងសំណុំរឿង ០០៤/២ និងសំណុំរឿង ០០៣ មិនមានសេចក្តីសម្រេចរួម លើអង្គសេចក្តីដែលគាំទ្រ និងបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចដែលវិធានរកសំឡេងមិនបាន បានស្នើឡើងនោះឡើយ។

៤. នៅក្នុងសំណុំរឿង ០០៤/២ ចៅក្រមជាតិសម្រេចថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះទុកជាមោឃៈ[5] ហើយតម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់ ចំណែកចៅក្រមអន្តរជាតិសម្រេចផ្ទុយពីនេះ[6]។ក្នុងសំណុំរឿង ០០៣ ចៅក្រមជាតិបញ្ជាក់ថា ដីកាដំណោះស្រាយទាំងពីរមានសុពលភាព ប៉ុន្តែបន្តបង្គាប់ឲ្យរក្សាទុកសំណុំរឿងក្នុងបណ្ណសារវិញ[7]។ ចៅក្រមអន្តរជាតិសម្រេចថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ចំណែកដីកាសម្រេចលើកលែងចោទប្រកាន់ គ្មានសុពលភាព[8] ហើយពួកគេលើកទឡ្ហីករណ៍ផងដែរថា ដោយសារតែចៅក្រមជាតិ បានសម្រេចថាដីកាដំណោះស្រាយទាំងពីរមានសុពលភាព គឺមានការឯកភាព

---

[4] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ មតិរបស់ចៅក្រម Olivier Beauvallet, និងចៅក្រម Kang Jin Baik កថាខណ្ឌ ២៥៥–២៦១, ៣៤៣។ សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ ការសម្រេចរួមគ្នានៅត្រង់ កថាខណ្ឌ ១១១–១១២ មតិរបស់ចៅក្រម Olivier Beauvallet, និងចៅក្រម Kang Jin Baik កថាខណ្ឌ ៣២២–៣២៣, ៦៨៥។

[5] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ២៩៤, ៣០២(៥)។

[6] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ មតិរបស់ចៅក្រម Olivier Beauvallet, និងចៅក្រម Kang Jin Baik កថាខណ្ឌ ៣១៨, ៣២៤, ៣២៦, ៦៨១, ៦៨៥–៦៨៦, ៦៩៥។

[7] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១១៥–១១៨។

[8] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ មតិរបស់ចៅក្រម Olivier Beauvallet, និងចៅក្រម Kang Jin Baik, កថាខណ្ឌ ១១៩, ២៤៩–២៥០, ២៥៩–២៦០, ២៦២, ២៨៤–២៨៥, ៣៤២។

ជាឯកច្ឆន្ទ លើសុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូច្នេះហើយសំណុំរឿងត្រូវបន្តនីតិវិធីទៅជំនុំជម្រះ ដោយសហចៅក្រមស៊ើបអង្កេត ចាំបាច់ត្រូវបញ្ជូនសំណុំរឿងជាផ្លូវការ[9]។

៥. នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើបន្ថែម តាមវិធាន ៨០(១) នៃវិធានផ្ទៃក្នុង តាមរយៈសារអេឡិចត្រូនិក ទៅអង្គជំនុំជម្រះសាលាដំបូង[10]។ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធសំណើតាមសារអេឡិចត្រូនិករបស់ក្រឡាបញ្ជីអង្គជំនុំជម្រះ នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០២១ដោយដកស្រង់ហេតុផលថាអង្គជំនុំជម្រះ មិនត្រូវបានជូនដំណឹងជាផ្លូវការអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ[11]។

## II. សារណា

៦. ដោយផ្អែកលើការសន្មតអំពីភាពជាឯកច្ឆន្ទនោះហើយ ទើបសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ "សំណើរបស់ខ្លួន មកកាន់សហចៅក្រមស៊ើបអង្កេត សុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង" ("សំណើ") នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ហើយត្រូវបានជូនដំណឹងនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២១[12]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ជាខ្លឹមសារថា៖

- ចៅក្រមអង្គបុរេជំនុំជម្រះទាំងប្រាំរូប បានសន្និដ្ឋានជាឯកច្ឆន្ទថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព[13]។

---

[9] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ មតិរបស់ចៅក្រម Olivier Beauvallet, និងចៅក្រម Kang Jin Baik, កថាខណ្ឌ ៣៤២–៣៤៣។

[10] *សំណើសុំបន្ថែមពេលវេលា ដើម្បីដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ តាមវិធាន៨០ នៃវិធានផ្ទៃក្នុង,* សារអេឡិចត្រូនិកពី Brenda Hollis សហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១, *សំណើសុំបន្ថែមពេលវេលា សម្រាប់ដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ* (មិនមានផ្តល់លេខឯកសារឬការចាត់ចំណាត់ថ្នាក់ឡើយ) ចម្លងជូនសហចៅក្រមស៊ើបអង្កេត។

[11] សារអេឡិចត្រូនិកពី លឹម ស៊ុយហុង ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ *Re: សំណើសុំបន្ថែមពេលវេលា សម្រាប់ដាក់បញ្ជូនឈ្មោះសាក្សី និងអ្នកជំនាញ* (មិនមានផ្តល់លេខឯកសារ ឬការចាត់ចំណាត់ថ្នាក់ឡើយ) ចម្លងជូនសហចៅក្រមស៊ើបអង្កេត។

[12] ឯកសារ D270 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១។

[13] ឯកសារ D270 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ កថាខណ្ឌ ១២។

. ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូង ត្រូវទទួលដោយស្វ័យប្រវត្តិ បន្ទាប់ពីការចេញសេចក្តីពិចារណា ក្នុងសំណុំរឿង ០០៣ អនុលោមតាមវិធាន ៧៧(១៣) និង ៧៩(១)[14]។

. អនុលោមតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត រួមគ្នា ឬតែម្នាក់ឯង ចាំបាច់ត្រូវបញ្ជូនភ្លាមៗនូវសេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង ទៅអង្គជំនុំជម្រះសាលាដំបូង[15]។

. អនុលោមតាមវិធាន ៦៩(២)(ក) នៃវិធានផ្ទៃក្នុង តាមករណីចាំបាច់ សហចៅក្រមស៊ើបអង្កេតដោយរួមគ្នា ឬតែម្នាក់ឯង ចាំបាច់ត្រូវបង្គាប់ដល់ផ្នែកគ្រប់គ្រងតុលាការ ឲ្យបញ្ជូនសេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង ទៅអង្គជំនុំជម្រះសាលាដំបូង[16]។

. ចាំបាច់ត្រូវមានការបញ្ជូនជាបន្ទាន់ អនុលោមតាមមាត្រា ១២(២) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៣ និង៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ២១(១) និង (៤) នៃវិធានផ្ទៃក្នុង[17]។

៧. នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ មេធាវីការពារក្តីបានឆ្លើយតប[18] (“ចម្លើយតប”) ដោយស្នើសុំឲ្យ ស.ច.ស សម្រេចទៅលើសំណើរបស់ ស.ព.អ ថាមិនអាចទទួលយកបាន ហើយគួរតែត្រូវបានច្រានចោលដោយសំអាងលើមូលដ្ឋានដូចខាងក្រោមនេះ៖

---

[14] ឯកសារ D270 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ កថាខណ្ឌ ១២។

[15] ឯកសារ D270 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ កថាខណ្ឌ ១៣, ១៦។

[16] ឯកសារ D270 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ កថាខណ្ឌ ១៣, ១៦។

[17] ឯកសារ D270 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ កថាខណ្ឌ ២, ១៥។

[18] ឯកសារ **D270/4** ចម្លើយតបរបស់ មាស មុត ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឲ្យបញ្ជូនសំណុំរឿង០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១។

- ដីកាដំណោះស្រាយទាំងពីរ គឺទុកជាមោឃៈ។ ហេតុនេះ ពុំមានដីកាបញ្ជូន រឿងទៅជំនុំជម្រះដែលមានសុពលភាព ត្រូវបញ្ជូនទៅ អ.ជ.ស.ដ ទេ[19]។
- ចៅក្រមអន្តរជាតិពុំបានផ្តល់នូវសំអាងហេតុសមហេតុផល ឬមូលដ្ឋាន សំអាងផ្លូវច្បាប់ ក្នុងការងាកចេញពីការសម្រេចរបស់**អង្គជំនុំជម្រះតុលាការកំពូល** (“អ.ជ.ត.ក”) ក្នុងសំណុំរឿង ០០៤/២[20] ឡើយ។
- អ.ប.ជ នៅតែទទួលពិនិត្យសំណុំរឿង និងជាស្ថាប័នតុលាការតែមួយគត់ដែលមានសិទ្ធិអំណាចបញ្ជូនសំណុំរឿងទៅ អ.ជ.ស.ដ[21]។
- អ.ប.ជ មិនអាចរកបានសំឡេងភាគច្រើនលើសលប់ដើម្បីសម្រេចថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាពនោះឡើយ។ អាស្រ័យហេតុនេះ មិនបានជូនដំណឹងនិងបញ្ជូនសំណុំរឿងទៅ អ.ជ.ស.ដអនុលោមតាមវិធាន ៧៩(១)នៃវិធានផ្ទៃក្នុងឡើយ[22]។

## III. ការពិភាក្សា

### ក. ការកត់សម្គាល់បឋម

៨. ទោះបីជាយើងអាចលើកឡើងពីបញ្ហាជាច្រើន អំពីទស្សនៈរបស់អង្គបុរេជំនុំជម្រះ ដែលបានលើកឡើងនៅក្នុងសេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ និង០០៣ក្តី តែយើងត្រូវផ្តោតទៅលើបញ្ហាចំនួនបីជាសំខាន់ចាំបាច់[23]។

---

[19] ឯកសារ **D270/4** ចម្លើយតបរបស់ មាស មុត ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឱ្យបញ្ជូនសំណុំរឿង០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ កថាខណ្ឌ ១៨-១៩។

[20] ឯកសារ **D270/4** ចម្លើយតបរបស់ មាស មុត ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឱ្យបញ្ជូនសំណុំរឿង០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ កថាខណ្ឌ ១៨, ២០-២១។

[21] ឯកសារ **D270/4** ចម្លើយតបរបស់ មាស មុត ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឱ្យបញ្ជូនសំណុំរឿង០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ កថាខណ្ឌ ១៨, ២២។

[22] ឯកសារ **D270/4** ចម្លើយតបរបស់ មាស មុត ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឱ្យបញ្ជូនសំណុំរឿង០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ កថាខណ្ឌ ១៨, ២៣។

[23] តាមពិតទៅ យើងយល់ស្របយ៉ាងច្រើនទៅនឹងការកំណត់ចរិតលក្ខណៈយ៉ាងទូលំទូលាយរបស់ចម្លើយតប អំពីការវិវត្តន៍នៃសំណុំរឿង និងទស្សនរបស់ អ.ប.ជ។

*១. សីលធម៌តុលាការ*

៩. ជាលើកទីពីរហើយដែលយើងត្រូវទទួលរងនូវភាសាយ៉ាងកំណាច និងការនិយាយបញ្ចិតបញ្ចៀង ដែលសឹងតែគ្មានការលាក់បាំងថា យើងចេញដីកាដំណោះស្រាយពីរ ក្នុងគោលបំណងធ្វើឲ្យខូចខាត ដល់ដំណើរការក្នុងសំណុំរឿង ០០៤/២ និង០០៣។ នាពេលនេះ អង្គបុរេជំនុំជម្រះ បានបន្ថែមឃ្លាមួយថា “ទម្រង់” មួយ បានកើតឡើងវិញ[24] ហើយថាយើងធ្វើឲ្យការប្រព្រឹត្តខុសកន្លងមករបស់យើង កាន់តែធ្ងន់ធ្ងរឡើង តាមរយៈការអនុវត្តឡើងជាថ្មីម្តងទៀត[25] បើទោះបីជាការពិតថា តាំងពីមុនពេលចេញសេចក្តីពិចារណា ក្នុងសំណុំរឿង ០០៤/២ ដីកាដំណោះស្រាយរបស់យើងទាំងអស់ត្រូវបានចេញ ហើយអង្គបុរេជំនុំជម្រះបានដឹងអំពីលក្ខណៈនៃសំណុំរឿងទាំងអស់។ ដោយសារតែវិធីសាស្ត្ររបស់យើង មានសង្គតភាព និងមានគោលការណ៍ ការកើតឡើងនូវ “ទម្រង់” នោះ មិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលឡើយ។

១០. ទោះបីជាយើងជ្រើសរើសយកការអត់ធ្មត់តាមផ្លូវតុលាការ នៅពេលក្រោយចេញសេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ របស់អង្គបុរេជំនុំជម្រះក្តី យើងយល់ឃើញថា ពេលនេះគឺជាពេលដែលយើង ត្រូវរំឭកដល់សហការីរបស់យើង នៅក្នុងអង្គបុរេជំនុំជម្រះ អំពីភារកិច្ចរបស់ខ្លួន តាមក្រមសីលធម៌តុលាការជាតិរៀងៗខ្លួន និងអំពីច្បាប់ទូទៅស្តីពីការបរិហារកេរ្តិ៍។

១១. យើងកម្រិតខ្លួនឯង ដោយយោងតែត្រឹមជំពូក VI និង VII នៃក្រមសីលធម៌តុលាការបារាំង[26] ជាពិសេសដោយសារតែភាពច្បាស់លាស់ល្អនៃក្រមនេះ។ ក្រមសីលធម៌នៃចៅក្រមកម្ពុជាឆ្នាំ ២០០៧ ទោះបីជាមិនបានចែងច្បាស់ក្តី ដោយប្រយោល ក៏បានហាមឃាត់នូវការបញ្ចេញយោបល់ជាសាធារណៈដោយចៅក្រម ដែលអាចប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃចៅក្រមដទៃផងដែរ។[27] ច្បាប់សាធារណរដ្ឋកូរ៉េ ក៏អាចរំពឹងថា មានខ្លឹមសារក៏មិនខុសគ្នាដែរ៖

> “ភារកិច្ចគោរពដល់កិត្តិយស ដែលកើតចេញពីការធ្វើសម្បថ។ តម្រូវឲ្យសហការី និងបុគ្គលិកប្រព្រឹត្ត និងប្រាស្រ័យទាក់ទង ជាមួយតតីយជន ក្នុងលក្ខណៈដែលសមស្របជាមួយ តួនាទីរបស់សមាជិកតុលាការ។ ១. សមាជិកតុលាការ ចាំបាច់ត្រូវជៀសវាង មិនប្រើប្រាស់ពាក្យសម្តី

---

[24] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ១០៨។

[25] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ១០៩។

[26] នៅត្រង់ www.conseil-superieur-magistrature.fr/publications/recueil-des-obligations-deontologiques។

[27] ក្រមសីលធម៌ចៅក្រមកម្ពុជា ឆ្នាំ ២០០៧, ប្រការ ១, ១៥ និង ២៤។

ឬមតិយោបល់ នៅក្នុងការទំនាក់ទំនង ជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ ដែលអាចធ្វើឱ្យខូចខាតដល់រូបភាព របស់ប្រព័ន្ធតុលាការ ដោយសារតែទម្រង់ ឬលក្ខណៈមិនសមហេតុផល នៃការទំនាក់ទំនងនោះ។ ២. សេរីភាពតុលាការមិនបានអនុញ្ញាត ឱ្យប្រើប្រាស់ពាក្យពេចន៍ ដែលផ្ទុយនិងកិត្តិយសឡើយ។[28]

សមាជិកតុលាការ ត្រូវបង្ហាញទេពកោសល្យ ក្នុងការទំនាក់ទំនងជាមួយគូភាគី សាក្សី បុគ្គលដែលចូលរួមក្នុងរដ្ឋបាលតុលាការ និងដៃគូរបស់ស្ថាប័នតុលាការ ដោយមានអាកប្បកិរិយា ក្នុងលក្ខណៈគោរពដល់កិត្តិយសបុគ្គល និងស្តាប់អ្នកដទៃ។ ទេពកោសល្យមានន័យថា អាកប្បកិរិយារបស់មនុស្សម្នាក់ ដែលបង្ហាញនូវគុណភាពនៃការអត់ធ្មត់ ឆន្ទានុសិទ្ធិ និងការពិចារណាដល់អ្នកដទៃ។ ការគោរពចំពោះគូភាគី៖ ១. សមាជិកតុលាការត្រូវបានហាមឃាត់ មិនឱ្យប្រើប្រាស់កាយវិការ ភាសានិយាយ ការបញ្ចេញយោបល់ឬមតិ ដែលមិនសមស្រប ក្អេងក្អាង ចំអកឡកឡឺយ រើសអើង គម្រាមកំហែង ឬប្រមាថ ទោះជាផ្ទាល់មាត់ក្តី ឬលាយលក្ខណ៍អក្សរក្តី។ ៦. នៅពេលអនុវត្តតួនាទីសិទ្ធិអំណាចរបស់ខ្លួន សមាជិកតុលាការត្រូវតែគោរព អ្នកណាដែលខ្លួនប្រាស្រ័យទាក់ទងជាមួយ ជាពិសេសបុគ្គលិករដ្ឋបាលតុលាការ និងសមាជិកតុលាការដទៃ និងអ្នកទាំងឡាយណាដែលជួយដល់រដ្ឋបាលតុលាការ”[29]

---

[28] *VI: Le devoir de dignité procède du serment. Il impose, à l'égard des tiers, des collègues et collaborateurs, une conduite et des propos conformes à l'état de magistrat.1. Le magistrat doit s'abstenir d'utiliser dans ses écrits, comme dans ses propos, des expressions ou des ommentaires qui, en raison de leur forme ou de leur caractère excessif, sont de nature à porter atteinte à l'image de la justice. 2. La liberté juridictionnelle n'autorise pas l'emploi de termes contraires à la dignité*នៅក្នុង www.conseil-superieur-magistrature.fr/sites/default/files/atoms/files/gb_compendium.pdf.។

[29] *VII: Le magistrat entretient des relations empreintes de délicatesse avec les justiciables, les témoins, les auxiliaires de justice et les partenaires de l'institution judiciaire, par un comportement respectueux de la dignité des personnes et par son écoute de l'autre. La délicatesse s'entend du comportement d'une person e qui manifeste des qualités de réserve, de discrétion et de prévenance envers autrui. Le respect du justiciable 1. Le magistrat s'interdit d'utiliser, dans ses écrits comme dans sa communication verbale ou non verbale, des gestes, des propos, des expressions ou commentaires déplacés, condescendants, vexatoires, discriminatoires, agressifs ou méprisants. Le respect des autres professionnels de justice 6. Dans l'exercice de ses fonctions d'autorité, le magistrat respecte ses interlocuteurs, notamment les magistrats et les fonctionnaires de greffe et l'ensemble de ceux qui concourent à l'œuvre de justice.* "នៅក្នុង www.conseil-superieur-magistrature.fr/sites/default/files/atoms/files/gb_compendium.pdf.។

១២. ការអះអាងម្តងហើយម្តងទៀត[30] របស់ចៅក្រមអង្គបុរេជំនុំជម្រះដែលថា យើង “សម្រេចដោយចេតនា” គេចវេសពីយន្តការខ្វែងយោបល់គ្នា ការអនុវត្តច្បាប់ ឬ គោលជំហរមិនឯកភាព ដែលពួកគេគិតថាពួកយើងចូលរួមក្នុងអ្វីដែលពួកគេជឿថា ជាការអនុវត្តខុស ជាភាសាបារាំង *“mauvaises pratiques”* ក្នុងសេចក្តីពិចារណាក្នុងសំណុំរឿង ០០៣[31] ហើយថាពួកយើងបំពេញកិច្ច ដោយមានចេតនាខុសច្បាប់ និងមានផែនការរំខានដល់កិច្ចដំណើរការនីតិវិធី ដើម្បីរារាំងមិនឲ្យយុត្តិធម៌ ដំណើរការទៅបាននោះ គឺមិនមានជា*ទស្សនៈផ្លូវច្បាប់*ឡើយ ប៉ុន្តែគឺជា សេចក្តីថ្លែងការណ៍នៃអង្គហេតុ នៅក្នុងបរិបទដទៃផ្សេងទៀត ដែលត្រូវបានចាត់ទុកថាជាការបរិហាកេរ្តិ៍យ៉ាងធ្ងន់ធ្ងរ៖ អ្វីដែលសហការីយើងនិយាយ ដោយមិនមានភស្តុតាងសូម្បីបន្តិចនោះ ក្រៅពីការបកស្រាយផ្ទាល់ខ្លួន ដោយលម្អៀងរបស់ពួកគេ ទៅលើព្រឹត្តិការណ៍ គឺចង់សំដៅយ៉ាងច្បាស់ថាពួកយើងបង្វែរដំណើរការយុត្តិធម៌នោះ គឺជាការចោទប្រកាន់ក្នុងវិជ្ជាជីវៈដ៏អាក្រក់បំផុត ដែលត្រូវបានធ្វើឡើងទៅលើចៅក្រម ហើយក៏មានន័យផងដែរជាការចោទប្រកាន់ថា ពួកយើងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

១៣.ម្យ៉ាង យើងនៅតែសង្ស័យថា នេះគឺជាការវាយតម្លៃដែលចៅក្រមនៃអង្គបុរេជំនុំជម្រះ ត្រូវបានតម្រូវឲ្យធ្វើ នៅពេលអនុវត្តយុត្តាធិការបណ្តឹងឧទ្ធរណ៍របស់ខ្លួន ដូច្នេះហើយគឺគ្មានសុភវិនិច្ឆ័យទាល់តែសោះ។ ម៉្យាងវិញទៀត ការលើកឡើងជាខ្លឹមសារ នូវប្រយោគដែលមានលក្ខណៈ បរិហាកេរ្តិ៍ធ្ងន់ធ្ងរខ្លាំងនោះ តាមការទទួលខុសត្រូវ ដែលចៅក្រមអង្គបុរេជំនុំជម្រះ ត្រូវបានការពារតាមមាត្រា ១៩ និងមាត្រា ២០ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តី នៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃ កម្ពុជាប្រជាធិបតេយ្យ (“កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក”) គឺមិនស្របទៅនឹងគោលការណ៍ ដែលបានដកស្រង់ពីខាងលើឡើយ ជាពិសេសការដាស់តឿនរំឭកដោយពាក្យសម្តីនៅត្រង់ *délicatesse*។ យើងក៏មិនគិតដែរថា ចៅក្រមគួរតែប្រព្រឹត្តដោយសេរី ទៅលើសហការីរបស់ពួកគេ ក្នុងលក្ខណៈដែលសមគួរ ទាបជាងគូភាគីនោះឡើយ។

---

[30] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ៩០, ១០៧–១០៩, សូមមើលផងដែរ សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ៥៤ (ជើងទំព័រ ១០២), ៩៩, ១២៣។

[31] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ១០៨, នៅក្នុង សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ ពួកគេប្រើប្រាស់ពាក្យ “អនុវត្តខុស" នៅត្រង់ កថាខណ្ឌ ៥៤ (ជើងទំព័រ ១០២) និង ១២៣។

១៤. យើងសង្ឃឹមយ៉ាងមុតមាំថា ការក្រើនរំឭកនេះ នឹងធានាថា ពួកយើង ភាគីនានា និងសាធារណជន នឹងជៀសផុតពីទស្សនីយភាពដែលគ្មានវិជ្ជាជីវៈ និងគ្មានកិត្តិយសបែបនេះសារជាថ្មី នៅក្នុងសេចក្តីសម្រេចនាពេលអនាគតរបស់អង្គបុរេជំនុំជម្រះ ហើយយើងលើកទឹកចិត្តដល់ចៅក្រមរបស់អង្គបុរេជំនុំជម្រះ ឲ្យត្រឡប់ទៅប្រកាន់យកមាយាទតុលាការដែលត្រឹមត្រូវ ដែលដូចគ្នានឹងការអត់ធ្មត់ដែលបង្ហាញដោយអង្គជំនុំជម្រះតុលាការកំពូល នៅក្នុងដីកាបិទបញ្ចប់ នាថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ក្នុងសំណុំរឿង ០០៤/២ នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូល ធ្វើការត្រួតពិនិត្យ និងរិះគន់ទៅដល់កំហុសផ្ទាល់ខ្លួនរបស់អង្គបុរេជំនុំជម្រះ ដែលមិនអាចចេញសេចក្តីសម្រេចស្ថាពរ[32]។

> មានការចាំបាច់រំឭកថា អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា "ក្នុងរឿងក្តីជាក់លាក់ នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង ដែលចែងថា ខ្លួនមានសិទ្ធិអំណាចក្នុងការចេញដីកាដំណោះស្រាយថ្មី ឬកែប្រែដីកាដំណោះស្រាយនោះ ដែលនឹងធ្វើជាមូលដ្ឋាន សម្រាប់ការជំនុំជម្រះ"។ សូមសង្កត់ធ្ងន់ថា ខ្លួន "បានសម្រេចរួចមកហើយថា អង្គបុរេជំនុំជម្រះបំពេញតួនាទីជាសភាស៊ើបសួរកម្ពុជា នៅ អ.វ.ត.ក ដែលនៅពេលបានទទួលដីកាលើកលែងចោទប្រកាន់ ដោយសារផលវិបាកនៃបណ្តឹងឧទ្ធរណ៍ ត្រូវស៊ើបអង្កេតរឿងក្តីដោយខ្លួនឯង"។ ការយល់ឃើញច្បាស់លាស់នេះ នឹងនាំអ្នកវិភាគសមហេតុផលអាចសន្និដ្ឋានបានថា អង្គបុរេជំនុំជម្រះបានដឹងអំពី សិទ្ធិអំណាចរបស់ខ្លួន ក្នុងការធ្វើលើសពីការប្រកាសភាពខុសច្បាប់ នៃស្ថានការណ៍ដែលពាក់ព័ន្ធ ទៅនឹងការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និងចេញដីកាដំណោះស្រាយ សុពលភាពរបស់ខ្លួនថ្មីមួយបាន។ ទោះជាយ៉ាងណាក្តី អង្គបុរេជំនុំជម្រះពុំបានជ្រើសរើសវិធីសាស្ត្របែបនេះទេ។ អង្គបុរេជំនុំជម្រះ បន្ទាប់ពីប្រកាសជា*ឯកច្ឆន្ទ*ថា "ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា របស់សហចៅក្រមស៊ើប

[32] សំណុំរឿងលេខ ០០៤/២ ឯកសារ **E004/2/1/1/2** *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការបញ្ចប់សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង* ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ កថាខណ្ឌ ៥២–៥៣, ៦១–៦២។

អង្កេត គឺខុសច្បាប់ ដោយរំលោភក្របខណ្ឌច្បាប់របស់ អ.វ.ត.ក" *គប្បីចាប់យកមួយជំហានបន្ថែមទៀត និងផ្តល់នូវការសម្រេចស្ថាពរជាក់ស្តែង*[33]។

*២. ការចោទប្រកាន់ពីភារកិច្ចរបស់យើង ក្នុងការដាក់ការខ្វែងយោបល់គ្នា ដើម្បីស្វែងរកដំណោះស្រាយ ទៅអង្គបុរេជំនុំជម្រះ*

១៥. តាមការបកស្រាយខាងលើ មតិយោបល់លើការចោទប្រកាន់ចម្បងរបស់អង្គបុរេជំនុំជម្រះ ទៅលើពួកយើង ដែលមិនដាក់ការខ្វែងយោបល់គ្នា ទៅអង្គបុរេជំនុំជម្រះ នាពេលនេះក៏មានទៅតាម លំដាប់លំដោយផងដែរ។ អង្គបុរេជំនុំជម្រះភាគច្រើន បានចោទប្រកាន់ពីភារកិច្ចរបស់ពួកយើង ក្នុងការដាក់បង្ហាញការខ្វែងយោបល់គ្នាលើយុត្តាធិការបុគ្គល ទៅអង្គបុរេជំនុំជម្រះ សម្រាប់ស្វែងរកដំណោះ ស្រាយ។ ប៉ុន្តែពួកយើងមិនអាចយល់បាន ពីការរិះគន់យ៉ាងឥតសំចៃ របស់អង្គបុរេជំនុំជម្រះ ក្នុងផ្នែកនេះឡើយ។ ចៅក្រមជាតិរបស់អង្គបុរេជំនុំជម្រះ ជាច្រើនលើកច្រើនសារ នៅក្នុងសំណុំរឿង ០០៣[34] ០០៤/២[35] ព្រម

---

[33] **សំណុំរឿងលេខ ០០៤/២ ឯកសារ E004/2/1/1/2** *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការបញ្ចប់សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង* ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ កថាខណ្ឌ ៦១ លប់ចោលជើងទំព័រ និងគូសបញ្ជាក់បន្ថែមនៅជួរចុងក្រោយ។

[34] សូមមើល ជាឧទាហរណ៍ឯកសារ **D120/3/1/8** *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងដីកាសម្រេចចេញសាឡើងវិញ លើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញាអន្តរជាតិ* ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦, យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ២៧។ ឯកសារ **D165/2/26** [សំណៅកោសលុបសាធារណៈ:] *សាលដីការបស់អង្គបុរេជំនុំជម្រះ ១) លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក់ព័ន្ធនឹងសំណើចំនួនប្រាំបួន របស់ មាស មុត សុំប្តឹងទៅអង្គបុរេជំនុំជម្រះ ឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និង ២) លើសំណើសុំចំនួនពីរ ដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ពាក់ព័ន្ធ សំណើសុំមោឃភាព ចំនួនប្រាំបួនរបស់ មាស មុត កថាខណ្ឌ ៩៦។ ឯកសារ **D87/2/1.7/1/1/7** [សំណៅកោសលុបសាធារណៈ:]*សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ជំទាស់ដីកាសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺ ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹង ជម្លោះប្រដាប់អាវុធ* ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ៧២។

[35] **សំណុំរឿងលេខ ០០៤/២ ឯកសារ D257/1/8** *សេចក្តីពិចារណាលើសំណើរបស់ អោ អាន សុំឱ្យអង្គបុរេជំនុំជម្រះ ធ្វើមោឃភាពកិច្ចស៊ើបអង្កេត ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ* ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១៤។ **សំណុំរឿងលេខ ០០៤/២ ឯកសារ D299/3/2** *សេចក្តី*

ទាំង០០៤/១ និង០០៤[36] បានបង្ហាញទស្សនៈរបស់ខ្លួនថា ពួកគាត់មិនទទួលស្គាល់ថា អ.វ.ត.ក មាន យុត្តាធិការទៅលើជនត្រូវចោទដែលនៅសល់ណាមួយផ្សេងឡើយ បន្ទាប់ពីសំណុំរឿង ០០១ និង០០២ គឺ តាំងពីមុនបិទបញ្ចប់ការស៊ើបអង្កេត ទៅលើសំណុំរឿងដែលនៅសេសសល់។ ចៅក្រមជាតិនៅរក្សាជំហរ ដដែល នៅពេលដែលចេញដីកាដំណោះស្រាយរបស់យើង ហើយមិនមានហេតុផលណាមួយ ដែលនាំឲ្យ

---

*ពិចារណាលើសំណើរបស់ អោ អាន សុំអង្គបុរេជំនុំជម្រះ ទទួលពិចារណាលើការធ្វើមោឃភាព កិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួល បេង និងវត្តអង្គញញី និងបទចោទនានាទាក់ទងនឹងទួលបេង* ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ៣៨។ **សំណុំរឿងលេខ ០០៤/២ ឯកសារ D263/1/5** *សេចក្តីពិចារណាលើ សំណើសុំរបស់ អោ អាន សុំមោឃភាពកិច្ចស៊ើបអង្កេត ទាក់ទងនឹងវត្តតាមាក់* ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ៤១។ **សំណុំរឿងលេខ ០០៤/២ ឯកសារ D260/1/1/3** *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើលើកទីប្រាំរបស់ អោ អាន សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃ ទី១៦ ខែមិថុនា ឆ្នាំ២០១៦ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធីយោបល់របស់ ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ២៩។ **សំណុំរឿងលេខ ០០៤/២ ឯកសារ D276/1/1/3** *សាលដីកាសម្រេច លើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេច លើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ លើក ទីប្រាំមួយរបស់ អោ អាន* ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ២៨។ **សំណុំរឿងលេខ ០០៤/២ ឯកសារ D320/1/1/4** *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកា សម្រេចលើសំណើសុំ បំពេញកិច្ចស៊ើបសួរលើកទី១២ របស់ អោ អាន* ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១៨។ **សំណុំរឿងលេខ ០០៤/២ ឯកសារ D277/1/1/4** *សាលដីកា លើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី៧ របស់ អោ អាន* ថ្ងៃទី៣ ខែមេសា ឆ្នាំ ២០១៧ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១៨។ **សំណុំរឿងលេខ ០០៤/២ ឯកសារ D343/4** *សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ ជំទាស់នឹងដីកាសម្រេច លើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ លើកទីដប់របស់ អោ អាន* ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និង ចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១៧, សូមមើលផងដែរ សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ កថាខណ្ឌ ២២៥, ២៥០–២៥១។

[36] សូមមើលជាឧទាហរណ៍ សំណុំរឿង ០០៤/១ ឯកសារ **D298/2/1/3** *សេចក្តីពិចារណាលើសំណើរបស់ អ៊ឹម ចែម សុំឲ្យធ្វើ មោឃភាពប្រតិចារឹក និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី* ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ទាក់ទងអង្គសេចក្តីនៃសំណើសុំ កថាខណ្ឌ ៣៩។ សំណុំរឿង ០០៤ ឯកសារ **D344/1/6** *សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅ ក្នុងស្រុកសង្កែ (តំបន់ ១)* ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និង ចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១៤។ សំណុំរឿង ០០៤ ឯកសារ **D345/1/6** *សេចក្តីពិចារណាលើសំណើរបស់ យឹម ទិត្យ សុំធ្វើ មោឃភាពកិច្ចស៊ើបសួរ និងដីកាទាក់ទងនឹងទំនប់កង្គួត* ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១៦។

គិតបានថា ពួកគេនឹងផ្លាស់ប្តូរចិត្តភ្លាមៗ បែបអច្ឆរិយៈដូចនេះ នៅក្នុងបរិបទនៃដីកាដំណោះស្រាយឡើយ។ ហេតុដូច្នេះមិនមានចំណុចណាមួយ ដែលជម្រុញឲ្យមាននីតិវិធីការខ្វែងយោបល់គ្នា លើយុត្តាធិការ នៅចំពោះមុខអង្គបុរេជំនុំជម្រះឡើយ ព្រោះលទ្ធផលគឺជាការសន្និដ្ឋាន ដែលចៀសមិនរួចនោះឡើយ។ ការធ្វើដូច្នេះគឺមានន័យថា ជាការពន្យារពេលដែលមិនចាំបាច់ និងការចំណាយពេលវេលា និងធនធានដោយឥតប្រយោជន៍ ដូចដែលសេចក្តីពិចារណា ក្នុងសំណុំរឿង ០០៣ និង០០៤/២ ពិតជាបានបង្ហាញយ៉ាងជាក់ច្បាស់រួចហើយ។ ប្រសិនបើយើងធ្វើនូវអ្វី ដែលអង្គបុរេជំនុំជម្រះតម្រូវ ពួកយើងគឺគ្រាន់តែត្រឡប់ក្រោយទៅចំណុចចាប់ផ្តើមវិញ រាប់ខែក្រោយមកប៉ុណ្ណោះ។

១៦. ក៏ប៉ុន្តែ ការសរសេរវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង បណ្តាលឲ្យមានបញ្ហា នៃការបកស្រាយលើបណ្តឹងឧទ្ធរណ៍នានា។ ការផ្តល់នូវការក្រើនរំឭកជាមុន អំពីភាពចាំបាច់ក្នុងការពិចារណា ភាពជាប់ពាក់ព័ន្ធ និងមិនមានអ្វីផ្សេងក្រៅពីនោះ គឺជាគោលបំណងនៃសេចក្តីជូនដំណឹងពីដំបូងរបស់យើង ជូនទៅភាគីនានា និងអង្គបុរេជំនុំជម្រះ អំពីបញ្ហានៅក្នុងសេចក្តីសម្រេច ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ដែលមិនមែនជាការប្រកាសមុនព្រឹត្តិការណ៍ (ex-ante announcement) អំពីគម្រោងផែន ការសម្ងាត់ទុច្ចរិត ណាមួយ ដើម្បីធ្វើឲ្យខូចខាតដល់រដ្ឋបាលតុលាការនោះទេ[37]។

១៧. យើងមិនប្រាកដថា តើអង្គបុរេជំនុំជម្រះចង់មានន័យយ៉ាងដូចម្តេច នៅក្នុងសំណុំរឿង០០៤/២ ហើយដែលទស្សនៈរបស់ពួកគេ ដែលបានលើកឡើងនាពេលនោះ ឥឡូវនេះបានវិលត្រឡប់មកវិញយ៉ាងច្បាស់ក្រឡែត នៅក្នុងសំណុំរឿង ០០៣ ថា ពួកយើងគួរតែបានលើកឡើងផងដែរអំពីចេតនារបស់យើង ក្នុងការចេញដីកាដំណោះស្រាយដាច់ពីគ្នា ដើម្បីទទួលបានដំណោះស្រាយ ដែលជាបញ្ហានៃច្បាប់ ឬយ៉ាងណា និងថាតើ អ្វីដែលជាផលវិបាកនៃការសម្រេចរបស់ពួកគេលើអនីត្យានុកូលភាព។

១៨. ជាដំបូង យើងយល់ស្រប អំពីសិទ្ធិរបស់ពួកយើង ក្នុងការចេញដីកាដំណោះស្រាយដាច់ពីគ្នាឡើយ ព្រោះយើងបានបង្ហាញយ៉ាងច្បាស់ល្អិតល្អន់ នៅក្នុងសេចក្តីសម្រេចរួមរបស់យើង កាលពីថ្ងៃទី១៨ ខែកញ្ញា

---

[37] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ ការសម្រេចរួមគ្នានៅត្រង់ កថាខណ្ឌ ៩០, ១០៧ –១០៩ មតិរបស់ចៅក្រម Olivier Beauvallet, និងចៅក្រម Kang Jin Baik, កថាខណ្ឌ ២៧៣, ២៧៥ សូមមើលផងដែរ សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២, កថាខណ្ឌ ៥៤ (ជើងទំព័រ ១០២) ៩៩, ១២៣។

ឆ្នាំ២០១៧ ក្នុងសំណុំរឿង ០០៤/២[38]។ ជាឧទាហរណ៍ យើងបានសង្ឃឹមជាធម្មតាថា ភាគីណាមួយនឹងប្ដឹងឧទ្ធរណ៍ ទៅលើសេចក្ដីសម្រេចនោះ ដើម្បីទទួលបានការសម្រេចដំបូង លើបញ្ហាគតិយុត្តិដ៏សំខាន់នោះ ពីអង្គបុរេជំនុំជម្រះ។ បើទោះបីជាបណ្ដឹងឧទ្ធរណ៍ ប្រហែលជានឹងមិនអាចទទួលយកបានក្ដី ក៏ការណ៍នេះនឹងផ្ដល់ឱកាសដល់អង្គបុរេជំនុំជម្រះ ក្នុងការចេញសេចក្ដីណែនាំ ក្នុងទម្រង់ជាការកត់សម្គាល់ (*obiter dictum*) នៅក្នុងសេចក្ដីពិចារណារបស់ខ្លួន ក្នុងសំណុំរឿង ០០៤/១[39] ដែលធ្វើឡើងបន្ទាប់ពី សេចក្ដីសម្រេចឆ្នាំ២០១៧ ដែលបានលើកឡើងពីខាងលើ ប៉ុន្តែនៅមុនដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ ដែលក្នុងនោះពួកគេពិភាក្សាអំពីភាពស្របច្បាប់ នៃការបំបែកដីកាដំណោះស្រាយ ទៅជាផ្នែកសម្រេចសេចក្ដី និងសំអាងហេតុបន្ទាប់ ដែលអង្គជំនុំជម្រះអាចចាត់ចំណាត់ថ្នាក់ *ជារួមគ្នា* (*per curiam*) ផងដែរថា ជាកំហុសឆ្គងនីតិវិធីដ៏ធ្ងន់ធ្ងរ[40]។

១៩. ប្រសិនបើអង្គបុរេជំនុំជម្រះ មានក្ដីបារម្ភធ្ងន់ធ្ងរជាសារវន្តបែបនេះ អំពីភាពស្របច្បាប់នៃដីកាដំណោះស្រាយផ្សេងពីគ្នា ក្នុងសំណុំរឿង ០០៤/២ ការណ៍នេះមិនអាចថាមិនអាចប្រមើលមើលដឹងជាមុនបាននោះឡើយ ហើយព្រឹត្តិការណ៍ជាក់ស្ដែងនាពេលថ្មីៗនេះ សម្រាប់ចៅក្រមអង្គបុរេជំនុំជម្រះ ដែលបានជួបប្រទះ នៅពេលព្រាងសេចក្ដីពិចារណាក្នុងសំណុំរឿង ០០៤/២ និងការជូនដំណឹង*ជាការកត់សម្គាល់* នៅក្នុងសំណុំរឿង ០០៤/១ ក្នុងកម្រិតនោះ គឺមានភាពប្រុងប្រយ័ត្នខ្ពស់ និងមានប្រយោជន៍ខ្លាំង ដោយមិនគិតអំពីការណ៍ដែល អ.ប.ជ ជារឿយៗមិនចង់ទាល់តែសោះក្នុងការចេញមតិយោបល់ណែនាំ (ត្រង់ចំណុចនេះ សូមមើល កថាខណ្ឌ ២០ ខាងក្រោម)។ ប្រសិនបើពួកយើងបានទទួលការជូនដំណឹងបែបនេះ អំពីមតិរួមគ្នារបស់អង្គបុរេជំនុំជម្រះ ក្នុងលក្ខណៈលឿនជាងនេះនោះ សំណុំរឿងដែលនៅសល់ទាំងអស់អាចនឹងត្រូវបានដោះស្រាយ ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន តាមរយៈសេចក្ដីសម្រេចរួមដែលអាចត្រឹមតែជាការបញ្ចប់ភ្លាមៗនូវសំណុំរឿងទាំងអស់ដែលនៅសេសសល់ បន្ទាប់ពីការលើកលែងចោទប្រកាន់នៅក្នុងសំណុំរឿង ០០៤/១ ដូចដែលយើងពន្យល់លម្អិតបន្ថែមទៀតខាងក្រោមនេះ។ ជាចុង

[38] **សំណុំរឿងលេខ ០០៤/២ ឯកសារ D355/1** *ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារ ដែលពាក់ព័ន្ធនឹងការខ្វែងយោបល់* ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ ៦–១៨។

[39] សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** *សេចក្ដីពិចារណាលើ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)* ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨។

[40] សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** *សេចក្ដីពិចារណាលើ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)* ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៣២–៣៥។

ក្រោយ ប៉ុន្តែសំខាន់ដូចគ្នានោះ ការណ៍នេះនឹងជួយធ្វើឲ្យពួកយើង ចំណេញពេលវេលា និងកម្លាំងយ៉ាងច្រើន និងនិយាយឲ្យចំទៅ ក៏ជួយសន្សំមួយផ្នែកធំ ដល់អ្នកផ្តល់ជំនួយអន្តរជាតិ និងរាជរដ្ឋាភិបាលកម្ពុជា លើការចូលរួមចំណែកផ្នែកហិរញ្ញវត្ថុរបស់ពួកគេ សម្រាប់ថវិការបស់ អ.វ.ត.ក។

២០. ទីពីរ បើទោះបីជាពួកយើងស្នើសុំដល់អង្គបុរេជំនុំជម្រះឲ្យចេញសេចក្តីសម្រេចលើបញ្ហា ភាពស្របច្បាប់នៃដីកាដំណោះស្រាយដាច់ពីគ្នាក្តី ប្រហែលជាពួកយើងទទួលបានព័ត៌មានមកវិញថា នេះមិនមែនជានីតិវិធីនៃការខ្វែងយោបល់គ្នានោះទេ តែជាសំណើសុំមតិប្រឹក្សា ជាអ្វីដែលអង្គបុរេជំនុំជម្រះ តាំងពីដំបូងមក[41] បដិសេធជារៀងរហូតមិនធ្វើការពិចារណា[42]។ ជាពិសេស គួរកត់សម្គាល់ថា មេធាវីការពារក្តី

---

[41] **សំណុំរឿង ០០២ ឯកសារ D345/5/11** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់ សហចៅក្រមស៊ើបអង្កេត សម្រេចលើសំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តី នៃការទទួលខុសត្រូវរបស់ថ្នាក់លើ* ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ១១ "សហចៅក្រមស៊ើបអង្កេតមិនជាប់កាតព្វកិច្ចក្នុងការធ្វើសេចក្តីសម្រេចបកស្រាយច្បាប់ ដូចដែលបានលើកឡើងយ៉ាងមានប្រសិទ្ធភាពនៅក្នុងសំណើសុំនេះទេ ហើយអង្គបុរេជំនុំជម្រះនឹងមិនផ្តល់គំនិតយោបល់បែបប្រឹក្សាណាមួយនោះទេ និងមិនអាចដាក់កំហិតសហចៅក្រមស៊ើបអង្កេតក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ទាក់ទងទៅនឹងសេចក្តីសម្រេចដែលត្រូវបញ្ជាក់ជូននៅក្នុងដីកាដំណោះស្រាយនោះ"។ [សេចក្តីបញ្ជាក់បន្ថែម]។

[42] សំណុំរឿងលេខ ០០៤-**D381/42** & **D382/41** ចក្តីសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ សុំឲ្យបដិសេធសេចក្តីសម្រេចលើផែនការសកម្មភាពរបស់អង្គភាពគាំពារការពារក្តី ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ កថាខណ្ឌ ១១ " អង្គជំនុំជម្រះសូមរំលឹកថា អង្គជំនុំជម្រះមិនផ្តល់មតិយោបល់ណែនាំឡើយ"។ **សំណុំរឿងលេខ ០០៤/២ ឯកសារ D359/17** & **D360/26** *សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការបន្តថវិការបស់ ក្រុមមេធាវីការពារក្តីលោក អោ អាន* ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៩ កថាខណ្ឌ ៦។ **សំណុំរឿងលេខ ០០៤/២ ឯកសារD347.1/1/7** *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងការជូនដំណឹង ស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធ របស់របបឬរដ្ឋមួយ* ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ កថាខណ្ឌ ១៦។ សំណុំរឿង ០០៤ ឯកសារ **D306/17.1/1/9** *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការជូនដំណឹង ស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធ របស់រដ្ឋឬរបបមួយ* ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ កថាខណ្ឌ ១៩ "អង្គបុរេជំនុំជម្រះសូមបញ្ជាក់ជាថ្មីថា អង្គជំនុំជម្រះនឹងមិនផ្តល់គំនិតយោបល់បែបប្រឹក្សាណាមួយនោះទេ និងមិនអាចដាក់កំហិតសហចៅក្រមស៊ើបអង្កេតក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ទាក់ទងទៅនឹងសេចក្តីសម្រេចដែលត្រូវបញ្ជាក់ជូននៅក្នុងដីកាដំណោះស្រាយនោះ"។ ឯកសារ **D158/1** [សំណៅកោសលុបសាធារណៈ] សេចក្តីសម្រេចលើសំណើសុំអង្គបុរេជំនុំជម្រះបកស្រាយទូលាយអំពីវិសាលភាពដែលអាចអនុញ្ញាតបាននៃបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ និងបញ្ជាក់បំភ្លឺអំពីនីតិវិធីមោឃភាពដីកាដំណោះស្រាយ ឬផ្នែកនានានៃដីកាដំណោះស្រាយ ប្រសិនបើចាំបាច់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ កថាខណ្ឌ ១៤ "អង្គបុរេជំនុំជម្រះពុំមានយុត្តាធិការដើម្បីដោះស្រាយបញ្ហាជាសម្មតិកម្ម ឬផ្តល់នូវមតិយោបល់ណែនាំនោះទេ"។ **សំណុំរឿង ០០៤/២ ឯកសារ D208/1/1/2**

យឹម ទិត្យ នៅក្នុងសំណុំរឿង ០០៤ កាលពីដើមខែសីហា ឆ្នាំ២០១៤ បានស្នើសុំឱ្យអង្គបុរេជំនុំជម្រះផ្តល់នូវការយល់ឃើញផ្ទាល់ខ្លួនអំពីបញ្ហាច្បាប់ជាក់លាក់ទាក់ទិននឹងបញ្ហានេះ ពោលគឺ "[i] ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតថាតើ ត្រូវលើកលែងការចោទប្រកាន់ប្រឆាំងនឹងម្ចាស់បណ្តឹងឧទ្ធរណ៍ ឬត្រូវចោទប្រកាន់បញ្ជូនគាត់ទៅជំនុំជម្រះ និង [ii] ... ក្នុងករណីដែលការខ្វែងយោបល់គ្នានៅចំពោះមុខអង្គបុរជំនុំជម្រះ ហើយ អ.ប.ជ មិនអាចរកសំឡេងភាគច្រើនលើសលប់បាន នៅពេលសម្រេចលើការខ្វែងយោបល់គ្នានោះ"។ អ.ប.ជ បានសម្រេច "ថា សេណារីយ៉ូដែលប្រមើលមើលនៅ

---

*សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងដីកាសម្រេចបដិសេធ សំណើរបស់គាត់ ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់ សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣*, ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ៨ "អង្គបុរេជំនុំជម្រះបានសង្កត់ធ្ងន់ថា វិធាន ២១ នៃវិធានផ្ទៃក្នុងមិនបានអនុញ្ញាតឱ្យខ្លួនដោះស្រាយបញ្ហាជាសម្មតិកម្ម ឬផ្តល់នូវមតិយោបល់ណែនាំនោះទេ"។ ឯកសារ **D117/1/1/2** [សំណៅកោសលុប សាធារណៈ] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៥។ សំណុំរឿង ០០៤ ឯកសារ **D212/1/2/2** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ជំទាស់ទៅនឹងការបំភ្លឺ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីសុពលភាពនៃដីកាកោះ ដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់* ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ៦, សំណុំរឿង ០០៤ ឯកសារ **D205/1/1/2** [សំណៅកោសលុប សាធារណៈ] *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធ សំណើរបស់គាត់សុំការបំភ្លឺ* ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ កថាខណ្ឌ ៧–៨ "អង្គបុរេជំនុំជម្រះពុំមានយុត្តាធិការដើម្បីដោះស្រាយបញ្ហាជាសម្មតិកម្ម ឬផ្តល់នូវមតិយោបល់ណែនាំនោះទេ"។ ឯកសារ **D87/2/2** [សំណៅកោសលុប សាធារណៈ] *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធតាមការសន្មត របស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ មាស មុត ចំនួនដប់បួនច្បាប់ ដែលបានដាក់ទៅ [ការិយាល័យសហចៅក្រមស៊ើបអង្កេត]* ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ២៥-២៦។ **សំណុំរឿង ០០២ ឯកសារ D345/5/11** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់ សហចៅក្រមស៊ើបអង្កេត សម្រេចលើសំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តី នៃការទទួលខុសត្រូវរបស់ថ្នាក់លើ* ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ១១ "សហចៅក្រមស៊ើបអង្កេតមិនជាប់កាតព្វកិច្ចក្នុងការធ្វើសេចក្តីសម្រេចបកស្រាយច្បាប់ ដូចដែលបានលើកឡើងយ៉ាងមានប្រសិទ្ធភាពនៅក្នុងសំណើសុំនេះទេ ហើយអង្គបុរេជំនុំជម្រះនឹងមិនផ្តល់គំនិតយោបល់បែបប្រឹក្សាណាមួយនោះទេ និងមិនអាចដាក់កំហិតសហចៅក្រមស៊ើបអង្កេតក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ទាក់ទងទៅនឹងសេចក្តីសម្រេចដែលត្រូវបញ្ជាក់ជូននៅក្នុងដីកាដំណោះស្រាយនោះ"។ សូមមើលផងដែរ ឯកសារ **D174/1/4**, [សំណៅកោសលុប សាធារណៈ] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ពីអំពើបំពារបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មថ្នាក់ជាតិ និងអនុវត្តសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ មតិយោបល់របស់ចៅក្រម Olivier Beauvallet និងចៅក្រម Judge Kang Jin Baik កថាខណ្ឌ ២៤ "ចៅក្រមដែលបានចុះហត្ថលេខានឹងមិនផ្តល់នូវមតិប្រឹក្សាឡើយ"។

ក្នុងសំណើនោះ ... គឺជាសម្មតិកម្ម" ហេតុនេះ អ.ប.ជ សម្រេចថា ខ្លួន "ពុំមានយុត្តាធិការដោះស្រាយបញ្ហាដែលជាសម្មតិកម្ម ឬផ្តល់នូវមតិយោបល់ណែនាំនោះទេ[43]។ ហេតុដូច្នេះ ការលើកឡើងណាមួយដែលថា ពួកយើងមានកាតព្វកិច្ចក្នុងការអះអាងនូវបញ្ហាច្បាប់ណាមួយនោះ គឺជារឿងចម្លែកបំផុត។

២១. ទីបី ដូចគ្នានឹងអង្គជំនុំជម្រះតុលាការកំពូល ពួកយើងវង្វេងវង្វាន់ ល្វែងដឹងថា តើចៅក្រមអង្គបុរេជំនុំជម្រះ អាចលើកឡើងរួមគ្នាដោយរបៀបណា នៅក្នុងសំណុំរឿង ០០៤/២ ថា ដីកាដំណោះស្រាយដាច់ពីគ្នា គឺខុសច្បាប់យ៉ាងច្បាស់ក្រឡែត និងជាការរំលោភបំពានទៅលើក្របខណ្ឌរបស់ អ.វ.ត.ក ដោយចៅក្រមជាតិ និងចៅក្រមអន្តរជាតិ បន្តពិភាក្សាលើអង្គសេចក្តី នៃដីកាដំណោះស្រាយនីមួយៗ ហើយឈានទៅដល់ការយល់ផ្សេងគ្នា ក្នុងការសម្រេចតម្កល់ដីកាដំណោះស្រាយ ដែលត្រូវបានប្តឹងឧទ្ធរណ៍ទៅកាន់ពួកគេនោះ។ ប្រសិនបើកំហុសរបស់ពួកយើង ក្នុងការចេញដីកាដំណោះស្រាយដាច់ពីគ្នា អាក្រក់បំផុតដូចបានរៀបរាប់យ៉ាងវែងដោយអង្គបុរេជំនុំជម្រះ នៅក្នុងសេចក្តីពិចារណាទាំងពីរនោះ ជាការដ៏ត្រឹមត្រូវបំផុត ដែលដីកាដំណោះស្រាយទាំងពីរ គួរតែត្រូវបានបដិសេធចោលភ្លាមៗ និងជាឯកច្ឆន្ទ ដោយសារតែវិការៈនីតិវិធីដ៏ធ្ងន់ធ្ងរ ដោយអង្គបុរេជំនុំជម្រះមិនចាំបាច់ចំណាយពេលវេលា លើការពិភាក្សាអំពីអង្គសេចក្តីឡើយ ហើយសំណុំរឿងត្រូវបង្វិលត្រឡប់មកពួកយើង ដោយមានសេចក្តីណែនាំមិនឲ្យ មានដីកាដំណោះស្រាយដាច់ពីគ្នា។ កំហុសនីតិវិធីនៃដីកា ដែលមានស្ថានទម្ងន់បែបនេះ នៅក្នុងសេចក្តីសម្រេចណាមួយ ក្នុងដំណាក់កាលស៊ើបអង្កេត ប្រាកដណាស់នឹងនាំទៅដល់ការធ្វើមោឃភាពដីកានោះ ហើយចាំបាច់ត្រូវលប់ចេញពីសំណុំរឿង ដោយសារតែមោឃភាព។ គោលជំហរដ៏គួរឲ្យភ្ញាក់ផ្អើល ដែលប្រកាន់យកដោយចៅក្រមអន្តរជាតិនៅក្នុងសេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ ដែលថាកំហុសនេះ មិនធ្វើឲ្យដីកាដំណោះស្រាយមោឃៈដោយខ្លួនឯងនោះ[44] គឺពិតជាពិបាកយល់ណាស់ ហើយការនេះត្រូវបានបង្ហាញផងដែរ ដោយទស្សនៈដែលអង្គជំនុំជម្រះតុលាការកំពូលប្រកាន់យក ក្នុងដីកាសម្រេចបញ្ចប់នៅក្នុងសំណុំរឿង ០០៤/២[45] ហើយដែល

---

[43] **សំណុំរឿងលេខ ០០៤-ឯកសារ D205/1/1/2** [សំណៅកោសលុបសាធារណៈ] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ កថាខណ្ឌ ៧-៨។

[44] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣, មតិរបស់ចៅក្រម Olivier Beauvallet, និងចៅក្រម Kang Jin Baik កថាខណ្ឌ ២៥៩, ២៦២, ២៨៤, ៣៩២។

[45] **សំណុំរឿងលេខ ០០៤/២ ឯកសារ E004/2/1/1/2** *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង* ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ កថាខណ្ឌ ៥២–៥៣, ៦១។

បច្ចុប្បន្ននេះ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានធ្វើការរិះគន់ផងដែរក្នុងលក្ខណៈគួរឲ្យសង្កៀរត្រចៀកយ៉ាងខ្លាំង[46]។

២២. ទីបួន តាមរយៈការតម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិក្នុងសំណុំរឿង ០០៤/២ នោះ ចៅក្រមជាតិ មិនបានគោរពទៅតាមសេចក្តីសម្រេចរួមរបស់ពួកគេផ្ទាល់នៅក្នុងកថាខណ្ឌ ១១១ និង ១១២ នៃសេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ ឡើយ ដែលថា តាមវិធានរកសំឡេងមិនបាន សំណុំរឿងត្រូវបន្តទៅមុខ។ តាមរយៈហេតុផលផ្ទាល់របស់ពួកគេ ចៅក្រមជាតិគួរតែចូលរួម ជាមួយសហការីអន្តរជាតិរបស់ខ្លួន ក្នុងការបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទៅអង្គជំនុំជម្រះសាលាដំបូង ហើយបញ្ហាថាតើវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ត្រូវអនុវត្តដោយផ្ទាល់ដែរឬអត់ ទៅលើសេណារីយ៉ូបច្ចុប្បន្ននេះ ចាំបាច់ត្រូវដែលដោះស្រាយ។ វិធានរកសំឡេងមិនបាន ដូចបានបង្ហាញ នៅក្នុងកថាខណ្ឌ ១១១ និង១១២ ពិតជាអាចសម្រេចលើបញ្ហា នៃភាពអាចអនុវត្តបាននៃវិធាន ៧៧(១៣)(ខ)។

២៣. ជាចុងក្រោយ មានតែផ្នែករួមគ្នានៃសេចក្តីពិចារណារបស់ អង្គបុរេជំនុំជម្រះប៉ុណ្ណោះ ដែលអាចមានអានុភាពចងកាតព្វកិច្ច ព្រោះផ្នែកនេះត្រូវបានព្រាងជាឯកច្ឆន្ទ។ ការទទូចទាមទាររបស់ ចៅក្រមអន្តរជាតិនៅក្នុងសំណុំរឿង ០០៤/២ និងសំណុំរឿង ០០៣ ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានសុពលភាព ហើយដីកាសម្រេចលើកលែងចោទប្រកាន់ គឺហួសពីសិទ្ធិអំណាច ឬ "មិនអនុលោមតាម" ច្បាប់ជាធរមាននោះ[47] គឺគ្រាន់តែដោយសារលទ្ធផលនោះ ស្របទៅតាមវិធានរកសំឡេងមិនបាន[48] គឺពិតជាមិនគួរឲ្យជឿជាក់បានឡើយ ដោយសារចៅក្រមជាតិ បើទោះបីជាអនុវត្តផ្ទុយទៅនឹងអ្វីដែលពួកគេបានសម្រេចរួមគ្នាជាមួយចៅក្រមអន្តរជាតិ បែរជាជ្រើសរើសយកការធ្វើដំណើរក្នុងទិសដៅផ្ទុយទៅវិញ។ ដូច្នេះហើយធ្វើឲ្យ

[46] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ មតិរបស់ចៅក្រម Olivier Beauvallet និងចៅក្រម Kang Jin Baik កថាខណ្ឌ ២៦៧–២៨៣។

[47] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ មតិរបស់ចៅក្រម Olivier Beauvallet និងចៅក្រម Kang Jin Baik កថាខណ្ឌ ១១៩, ២៤៩–២៥០, ២៥៩–២៦០, ២៦២, ២៨៤–២៨៥, ៣៤២។ សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២, មតិរបស់ចៅក្រម Olivier Beauvallet និងចៅក្រម Kang Jin Baik កថាខណ្ឌ ៣១៨, ៣២៤, ៣២៦, ៦៨១–៦៨២, ៦៨៥, ៦៩៤។

[48] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ មតិរបស់ចៅក្រម Olivier Beauvallet និងចៅក្រម Kang Jin Baik កថាខណ្ឌ ២៥៧, ២៦១–២៦២, ២៨៤។ សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ មតិរបស់ចៅក្រម Olivier Beauvallet និងចៅក្រម Kang Jin Baik កថាខណ្ឌ ៣២២-៣៣៣, ៦៨៥។

អង្គសេចក្តី និងការឈានទៅសម្រេចតាមវិធានរកសំឡេងមិនបាន គឺស្ថិតក្នុងមន្ទិលសង្ស័យ។ ដោយសារតែមិនមានសម្លេងភាគច្រើនលើសលប់ ទើបទស្សនៈនីមួយៗនៅចុងបញ្ចប់ គឺគ្មានអ្វីទាំងអស់តាមនីតិវិធី ដោយទស្សនៈនោះ គ្រាន់តែជាការបកស្រាយជាលក្ខណៈបុគ្គលរបស់ចៅក្រមជាតិ ឬចៅក្រមអន្តរជាតិប៉ុណ្ណោះ។

២៤. ការពិតដែលថា ដោយសារហេតុផលដែលយើងមិនបានដឹង ចៅក្រមជាតិធ្វើការបត់ត្រឡប់ក្រោយជាភាសា (U-turn) ដោយលើកឡើងក្នុងសំណុំរឿង ០០៣ ថា ដីកាដំណោះស្រាយទាំងពីរ មានសុពលភាពនោះ គឺមិនអាចផ្លាស់ប្តូរសេចក្តីសន្និដ្ឋាននោះឡើយ ព្រោះពួកគាត់នៅតែបន្ត ហើយផ្តល់ដោយផ្ទាល់នូវសេចក្តីណែនាំរដ្ឋបាលថា សំណុំរឿង ០០៣ ត្រូវរក្សាទុកក្នុងបណ្ណាសារ[49]។

២៥. សរុបមក ស្ថានភាពទាល់ច្រក ដែលមានកន្លងមកក្នុងសំណុំរឿង ០០៤/២ និងបច្ចុប្បន្ននេះ ក្នុងសំណុំរឿង ០០៣ គឺនៅទីបញ្ចប់ដោយសារតែការសម្រេចផ្ទាល់ខ្លួន របស់អង្គបុរេជំនុំជម្រះ ពីព្រោះដូចគ្នានឹងសំណុំរឿង ០០៤/២ អង្គបុរេជំនុំជម្រះជ្រើសរើសយក ការបញ្ចូលគ្នានូវការសម្រេចលើកំហុសនីតិវិធី គឺលើអ្វីដែលចៅក្រម អង្គបុរេជំនុំជម្រះទាំងអស់ យល់ព្រមជាមួយការសម្រេចលើអង្គសេចក្តី ដែលពួកគេដឹងតាំងពីមុនមកថា ពួកគេមិនត្រូវធ្វើដូច្នេះឡើយ។ នៅក្នុងសំណុំរឿង ០០៤/១ នៅចុងបញ្ចប់ពុំមានព្យសនកម្មឡើយ ដោយសារតែយើងបានសម្រេចរួមគ្នាលើកលែងចោទប្រកាន់ ហើយលទ្ធផលលើអង្គសេចក្តីគឺមានលក្ខណៈច្បាស់តាំងពីដំបូង។ ករណីដូចគ្នានេះ ពិតជាមិនអាចកើតមានឡើងឡើយចំពោះរឿងក្តីដែលយើងមិនឯកភាពគ្នា។ ដូច្នេះ អង្គបុរេជំនុំជម្រះមានឱកាសដល់ទៅពីរដង ក្នុងការលប់បំបាត់ភាពទាល់ច្រកដោយខ្លួនឯង តាមលក្ខណៈផ្សេងៗគ្នាបីយ៉ាងគឺ៖

. ជាឯកច្ឆន្ទបង្វិលត្រឡប់សំណុំរឿង មកពួកយើងវិញ ដោយសារតែកំហុសនីតិវិធីធ្ងន់ធ្ងរ ហើយមិនចាំបាច់ពាក់ព័ន្ធជាមួយអង្គសេចក្តីឡើយ ដោយមានសេចក្តីណែនាំឲ្យចេញដីកាដំណោះស្រាយតែមួយរួមគ្នា

. ឬ បំពេញកិច្ចដោយខ្លួនឯងផ្ទាល់ជាឯកច្ឆន្ទ ដោយអនុវត្តវិធានរកសំឡេងមិនបាន ហើយបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

---

[49] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១១៥–១១៨។

. ឬ ដោយសារតែការខ្វែងយោបល់គ្នា ដែលនៅមានជាក់ស្តែងនៅក្នុងអង្គបុរេជំនុំជម្រះ ដែលបង្ហាញតាមរយៈ សេចក្តីពិចារណាទាំងពីរនោះ ធ្វើការបិទបញ្ចប់សំណុំរឿង ដូចដែលអង្គជំនុំជម្រះតុលាការកំពូល បានសម្រេចជាស្ថាពរ ក្នុងសំណុំរឿង ០០៤/២[50]

អង្គជំនុំជម្រះតុលាការកំពូល បញ្ជាក់ច្បាស់លាស់នៅក្នុងសំណុំរឿង ០០៤/២ ថា អង្គបុរេជំនុំជម្រះត្រូវតែជ្រើសរើសការសម្រេចសេចក្តីចុងក្រោយ សម្រាប់សំណុំរឿងនៅចំពោះមុខខ្លួន។ ប៉ុន្តែដូចគ្នានឹងក្នុងសំណុំរឿង ០០៤/២ ជាថ្មីម្តងទៀត អង្គបុរេជំនុំជម្រះត្រូវប្រឈមជាមួយការសម្រេចផ្ទុយរបស់អង្គជំនុំជម្រះតុលាការកំពូល ដោយការជ្រើសរើសមិនអនុវត្ត តាមចំណុចណាមួយខាងលើឡើយ។ ជំនួសឲ្យការជ្រើសយកការបញ្ចេញយោបល់ដ៏វែងអន្លាយជាថ្មីទៀត អំពីអសមត្ថភាពផ្លូវច្បាប់ និងលក្ខណៈសីលធម៌របស់យើងដែលចោទជាបញ្ហានោះ បែរជាបង្កើតឲ្យមាននូវស្ថានភាពបច្ចុប្បន្ន ដោយមិនមានគោលដៅច្បាស់លាស់ និងបង្កើតឡើងនូវក្តីមន្ទិលធ្ងន់ធ្ងរ អំពីអត្ថន័យជាក់ស្តែងនៃវិធានរកសំឡេងមិនបាន ដូច្នេះជាលទ្ធផលគឺបោះបង់ចោលការទទួលខុសត្រូវ សម្រាប់ដំណោះស្រាយត្រឹមត្រូវចំពោះសំណុំរឿង ដែលមានផលវិបាកធ្ងន់ធ្ងរ ចំពោះសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ របស់ក្រុមការពារក្តី ដូចដែលយើងនឹងពន្យល់នៅក្នុងផ្នែក៣ ខាងក្រោម។

### *៣. សិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌ គឺការសម្រេចជាស្ថាពរលើសំណុំរឿង ដោយឆាប់រហ័ស*

២៦. កិច្ចដំណើរការនីតិវិធីប្រឆាំង មាស មុត នឹងស្ថិតនៅជាការង់ចាំជារៀងរហូត ដោយមិនមានដំណោះស្រាយ ប្រសិនបើស្ថានភាពបន្ទាប់ពីសេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ ដូចបានរៀបរាប់ពីខាងលើ គឺជាដំណាក់កាលចុងក្រោយនោះ។ មាស មុត មានសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌

---

[50] **សំណុំរឿងលេខ ០០៤/២ ឯកសារ E004/2/1/1/2** *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការបញ្ចប់សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង* ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ កថាខណ្ឌ ៦៩, ៧១ (vi)។

ក្នុងការទទួលបានការសម្រេចជាស្ថាពរ និងឆាប់រហ័ស ទៅលើសំណុំរឿងប្រឆាំងរូបគាត់[51]។ សិទ្ធិនេះមានចែងនៅក្នុងមាត្រា ១៤(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែល "រៀបចំឡើងដើម្បីរារាំង កុំឲ្យនរណាម្នាក់ដែលត្រូវបានចោទប្រកាន់ ពីបទល្មើសព្រហ្មទណ្ឌ ក្នុងរយៈពេលយូរខ្លាំងពេកនោះ ស្ថិតក្នុងស្ថានភាពមិនប្រាកដប្រជា អំពីជោគវាសនារបស់ខ្លួន"[52]។ រឿងក្តី *Marini*[53] របស់តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ពីឆ្នាំ២០០៧ ដែលជាអត្ថបទគួរឲ្យជឿជាក់ ផ្អែកលើបទប្បញ្ញត្តិមាត្រា ៦(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ដែលចែងពីសិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌ គឺ

---

[51] សូមមើលជាឧទាហរណ៍ មាត្រា ៣៣ថ្មី ៣៥ថ្មី(គ) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា យោងទៅរកមាត្រា ១៤(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ សូមមើលផងដែរជាឯកសារជម្រុញគាំទ្រ មាត្រា ៦(១) នៃតុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស និងអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស *Marini តទល់នឹង Albania* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីបួន សំណើសុំលេខ 3738/02 សាលក្រម ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧) កថាខណ្ឌ ១២០ និងបន្តបន្ទាប់។ ច្បាប់ប្រទេសអាល់បានីនៅពេលនោះ មានអានុភាពបណ្តាលឲ្យ មានការផ្អាកដោយគ្មានកំណត់ ចំពោះបណ្តឹងឧទ្ធរណ៍តាមរដ្ឋធម្មនុញ្ញនៅក្នុងរឿងក្តី ការបោះឆ្នោតស្មើគ្នា៖ ការលើកលែងចោទប្រកាន់ជាផ្លូវការ ដែលកំណត់ដោយសម្លេងឆ្នោតស្មើគ្នា មិនបានរារាំងអ្នកដាក់ពាក្យសុំ មិនឲ្យដាក់បណ្តឹងឧទ្ធរណ៍ដដែលឡើងវិញ រហូតទាល់តែសំអាងហេតុ ដែលបណ្តាលឲ្យមានសម្លេងឆ្នោតស្មើគ្នា លែងកើតមាន ដូចជាអាចទទួលបាន សម្លេងឆ្នោតច្រើនលើសលប់ជាដើម (នៅត្រង់ កថាខណ្ឌ ៧២, ៧៦)។ ភាពពាក់ព័ន្ធជាពិសេស នៅក្នុងបរិបទនៃរឿងក្តីបច្ចុប្បន្ន ក្នុងកថាខណ្ឌ ១២៣៖ "...តុលាការនឹងសង្កេតមើលថា វិធីសាស្ត្រដែលបានអនុម័ត នៅក្នុងប្រទេសអាល់បានី នៅក្នុងហេតុការណ៍សម្លេងឆ្នោតស្មើគ្នា គឺហាក់ដូចជាខុសប្លែកខ្លាំងពី វិធីសាស្ត្រដែលបានអនុម័ត នៅក្នុងប្រព័ន្ធច្បាប់នៃរដ្ឋជាភាគីដទៃ... ផ្ទុយពីប្រព័ន្ធច្បាប់ដទៃ ដែលមិនឲ្យមានសម្លេងឆ្នោតស្មើគ្នា ឬផ្តល់នូវជម្រើសផ្សេង ដើម្បីធ្វើឲ្យមានសេចក្តីសម្រេចស្ថាពរ នៅក្នុងករណីដែលមានសម្លេងឆ្នោតបែបនេះ នៅក្នុងប្រព័ន្ធច្បាប់អាល់បានី សម្លេងឆ្នោតស្មើគ្នា នៅក្នុងតុលាការធម្មនុញ្ញ បណ្តាលឲ្យមានសេចក្តីសម្រេច ដែលមិនបានបញ្ចប់ជាផ្លូវការ នូវបញ្ហាដែលស្ថិតក្នុងបណ្តឹងសាទុក្ខ។ បន្ថែមលើនេះ មិនមានការផ្តល់សំអាងហេតុណាមួយ សម្រាប់ការបដិសេធបណ្តឹងសាទុក្ខ នៅក្នុងហេតុការណ៍បែបនេះឡើយ ក្រៅពីថាសម្លេងឆ្នោតស្មើគ្នា។ ដោយបានពិចារណាទៅលើសេចក្តីពិចារណាខាងលើ តុលាការអាចត្រឹមសន្និដ្ឋានថា ការរៀបចំនូវសម្លេងឆ្នោតស្មើគ្នា... មិនបានបម្រើដល់ផលប្រយោជន៍របស់សច្ចភាពគតិយុត្តិ និងអាចដកហូតពីអ្នកដាក់ពាក្យសុំ នូវសិទ្ធិប្រកបដោយប្រសិទ្ធភាព ក្នុងការទទួលបានការសម្រេចស្ថាពរលើបណ្តឹងសាទុក្ខស្របតាមរដ្ឋធម្មនុញ្ញរបស់ខ្លួន"។

[52] Paul M Taylor, *បទអត្ថាធិប្បាយស្តីពី កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖ ការត្រួតពិនិត្យរបស់គណៈកម្មការសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ ទៅលើសិទ្ធិនៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* (Cambridge University Press, 2020) ទំព័រ ៤០៥។

[53] រឿងក្តី *Marini តទល់នឹង អាល់បានី* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីបួន សំណើសុំលេខ 3738/02 សាលក្រម ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧) កថាខណ្ឌ ១២០។

ជាការតំណាងនូវយុត្តិសាស្ត្រដែលមានរយៈពេលយូរអង្វែងរបស់តុលាការនោះ[54]។ នៅក្នុងរឿងក្តី *Marini* សូម្បីនៅក្នុងករណីនៃប្រព័ន្ធដែលភ្ជាប់ការបោះឆ្នោតសម្លេងស្មើគ្នា ថា ជាការបដិសេធផ្លូវការទៅលើសំណើ

---

[54] រឿងក្តី *Garcia Manibardo តទល់នឹង អេស្ប៉ាញ* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីបួន សំណើសុំលេខ 38695/97សាលក្រម ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០) កថាខណ្ឌ ៤៣,រឿងក្តី *Frydlender តទល់នឹង ប្រទេសបារាំង* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស Grand Chamber សំណើសុំលេខ 30979/96 សាលក្រម ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០) កថាខណ្ឌ ៤៥ ដកស្រង់ រឿងក្តី *Caillot តទល់នឹងប្រទេសបារាំង* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីបី សំណើសុំលេខ 36932/97 សាលក្រម ថ្ងៃទី៤ ខែមិថុនា ឆ្នាំ1999) កថាខណ្ឌ ២៧,រឿងក្តី *Kutic តទល់នឹង ប្រទេសក្រូអាត* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីមួយ សំណើសុំលេខ 48778/99 សាលក្រម ថ្ងៃទី១ ខែមីនា ឆ្នាំ២០០២ 2) កថាខណ្ឌ ២៥ រឿងក្តី *Multiplex តទល់នឹង ប្រទេសក្រូអាត* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីមួយ សំណើសុំលេខ 58112/00 សាលក្រម ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៣) កថាខណ្ឌ ៤៥ រឿងក្តី *Dubinskaya តទល់នឹង* ប្រទេសរុស្ស៊ី (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីមួយ សំណើសុំលេខ 4856/03 សាលក្រម ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦) កថាខណ្ឌ ៤១ ដកស្រង់ រឿងក្តី *Sukhorubchenko តទល់នឹង*ប្រទេសរុស្ស៊ី (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីមួយ សំណើសុំលេខ 69315/01 សាលក្រម ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០០៥) កថាខណ្ឌ ៥៣, រឿងក្តី *Kabkov តទល់នឹង* ប្រទេសរុស្ស៊ី (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីមួយ សំណើសុំលេខ 12377/03 សាលក្រម ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨) កថាខណ្ឌ ៤២ រឿងក្តី *Kostadin Mihaylov តទល់នឹង ប្រទេសប៊ុលហ្គារី* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីប្រាំ សំណើសុំលេខ 17868/07សាលក្រម ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៨) កថាខណ្ឌ ៣៨ រឿងក្តី *Bulanov តទល់នឹង ប្រទេសអ៊ុយក្រែន* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីប្រាំ សំណើសុំលេខ 7714/06 សាលក្រម ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១០) កថាខណ្ឌ ៣៦ រឿងក្តី *Menshakova តទល់នឹង ប្រទេសអ៊ុយក្រែន* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីប្រាំ សំណើសុំលេខ 377/02 សាលក្រម ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០) កថាខណ្ឌ ៥២, រឿងក្តី *Chuykina តទល់នឹង ប្រទេសអ៊ុយក្រែន* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីប្រាំ សំណើសុំលេខ 28924/04 សាលក្រម ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១) កថាខណ្ឌ ៥០, រឿងក្តី *Muscat តទល់នឹង ម៉ាល់តា* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីបួន សំណើសុំលេខ 24197/10 សាលក្រម ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២) កថាខណ្ឌ ៤៥, រឿងក្តី *Camovski តទល់នឹង ប្រទេសក្រូអាត* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីមួយ សំណើសុំលេខ 38280/10 សាលក្រម ថ្ងៃទី២៣ ខែតុលា ឆ្នាំ ២០១២) កថាខណ្ឌ ៣៩, រឿងក្តី *Deguara Caruana Gatto និងអ្នកដទៃទៀត តទល់នឹង ម៉ាល់តា* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីបួន សំណើសុំលេខ 14796/11សាលក្រម ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៣) កថាខណ្ឌ ៨៨, រឿងក្តី *Perusko តទល់នឹង ប្រទេសក្រូអាត* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីមួយ សំណើសុំលេខ 36998/09 សាលក្រម ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣) កថាខណ្ឌ ៤៨, រឿងក្តី *Avdic និងអ្នកដទៃទៀត តទល់នឹង បូស្នី និងហឺសេហ្គោវីន* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីបួន សំណើសុំលេខ 28357/11, 31549/11, 39295/11សាលក្រម ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣) កថាខណ្ឌ ៣៧ រឿងក្តី *Patrinjei តទល់នឹង ប្រទេសរ៉ូម៉ានី* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីបី សំណើសុំលេខ 54950/07 សាលក្រម ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤) កថាខណ្ឌ ៣៣ រឿងក្តី *Falie តទល់នឹង ប្រទេសរ៉ូម៉ានី* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីបី សំណើសុំលេខ 23257/04 សាលក្រម ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥) កថាខណ្ឌ ២២, ២៤, រឿងក្តី *Kardos តទល់នឹង ប្រទេសក្រូអាត* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីពីរ សំណើសុំលេខ 25782/11 សាលក្រម ថ្ងៃ

ប៉ុន្តែទុកឲ្យរឿងក្តី នៅបើកចំហរ *ដើម្បីអ្នកដាក់ពាក្យសុំ* អាចដាក់សំណើឡើងវិញនៅពេលក្រោយនោះ ក៏តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស មើលឃើញថាជាការរំលោភបំពានដែរ ទៅលើមាត្រា ៦(១) នៃវិធាន អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។ យុត្តិសាស្ត្រនិងបទប្បញ្ញត្តិ ពីតុលាការនិងអង្គជំនុំជម្រះអន្តរជាតិឬ មាន លក្ខណៈអន្តរជាតិដទៃទៀត ស្តីពីការជាប់គាំងក្នុងការបោះឆ្នោត និងការពិភាក្សាសម្រេចជាដើម[55] មិនបាន

---

ទី២៦ ខែមេសា ឆ្នាំ២០១៦) កថាខណ្ឌ ៤៨, រឿងក្តី *Lupeni Greek Catholic Parish និងអ្នកដទៃទៀត តទល់នឹង ប្រទេសរ៉ូម៉ានី* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស Grand Chamber សំណើសុំលេខ 76943/11 សាលក្រម ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦) កថាខណ្ឌ ៨៦ រឿងក្តី *Leuska និងអ្នកដទៃទៀត តទល់នឹង អេស្តូនី* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីពីរ សំណើសុំលេខ 64734/11 សាលក្រម ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៧) កថាខណ្ឌ ៦៧, រឿងក្តី *Muic តទល់នឹង ប្រទេសក្រូអាត* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីពីរ សំណើសុំលេខ 79653/12 សាលក្រម ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧) កថាខណ្ឌ ៤៤, រឿងក្តី *Centre for the Development of Analytical Psychology តទល់នឹង The Former Yugoslav Republic of Macedonia* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីមួយ សំណើសុំលេខ 29545/10 សាលក្រម ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០១៧) កថាខណ្ឌ ៤៥, រឿងក្តី *Regner តទល់នឹង សាធារណរដ្ឋឆែក* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស Grand Chamber, សំណើសុំលេខ 35289/11សាលក្រម ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៧) កថាខណ្ឌ ៩៩–១១២ រឿងក្តី *Tordaj តទល់នឹង សែប៊ី* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីបី សំណើសុំលេខ 19728/08 សាលក្រម ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៧) កថាខណ្ឌ ១៧, រឿងក្តី *Lesciukaitis តទល់នឹង លីទុយអានី* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីបួន សំណើសុំលេខ 72253/11 សាលក្រម ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧) កថាខណ្ឌ ៣៧, រឿងក្តី *Kamenova តទល់នឹង ប្រទេសប៊ុលហ្គារី* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីប្រាំ សំណើសុំលេខ 62784/09 សាលក្រម ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨) កថាខណ្ឌ ៤១, រឿងក្តី *Kristiana Ltd តទល់នឹង លីទុយអានី* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីបួន សំណើសុំលេខ 36184/13 សាលក្រម ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៨) កថាខណ្ឌ ១២២, រឿងក្តី *Brajovic និងអ្នកដទៃទៀត តទល់នឹង ម៉ុងតេណេក្រូ* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីពីរ សំណើសុំលេខ 52529/12សាលក្រម ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨) កថាខណ្ឌ ៤៨, រឿងក្តី *Kandarakis តទល់នឹង ប្រទេសក្រិក* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីមួយ សំណើសុំលេខ 48345/12, 48348/12, 67463/12 សាលក្រម ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០) កថាខណ្ឌ ៤៦, រឿងក្តី *Kocaman តទល់នឹងប្រទេសទួគី* (តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ផ្នែកទីពីរ សំណើសុំលេខ 77043/12 សាលក្រម ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០)។

[55] ប្រៀបធៀប *រដ្ឋអាជ្ញាតទល់នឹង Samil Jamil Ayyash* សេចក្តីសម្រេចលើ "បណ្តឹងសាទុក្ខប្រឆាំងដីកាសម្រេច របស់ចៅក្រមប្រធាន ចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូង II" តុលាការ STL អង្គជំនុំជម្រះតុលាការកំពូល (STL-18-10/MISC.2/AC, F0006) ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ១១ ១៦–២៤ តុលាការពិសេសដែលនៅសេសសល់ សម្រាប់ប្រទេសសេរ៉ាឡេអូន (Residual Special Court for Sierra Leone) *វិធានស្តីពីនីតិវិធី និងភស្តុតាង* (វិសោធនកម្មថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៤) (ចូលជាធរមាន ថ្ងៃទី១២ ខែមេសា ឆ្នាំ២០០២) r 16(B)(ii), ធម្មនុញ្ញតុលាការយោធាអន្តរជាតិ ឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀង ស្តីពីការជំនុំជម្រះ និងដាក់ទណ្ឌកម្ម ចំពោះឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ នៃអ័ក្សអឺរ៉ុប ("កិច្ចព្រមព្រៀងទីក្រុងឡុង") (ថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៤៥) (*"ធម្មនុញ្ញាតុលាការ Nuremberg"*) មាត្រា ២។

01671531



ផ្តល់នូវគោលការណ៍ណែនាំឡើយ សម្រាប់បរិបទពិសេសរបស់យើង គឺជាករណីដែលការជាប់គាំងនៅក្នុងអង្គជំនុំជម្រះ រួមគ្នាជាមួយការជាប់គាំង នៅតាមឋានានុក្រមដទៃផ្សេងទៀត នៃតុលាការជាច្រើនជាន់។ ស្ថានភាពបច្ចុប្បន្ន គឺជានិច្ចកាលជាផលវិបាកនៃលក្ខណៈពិសេសចម្រុះរបស់ អ.វ.ត.ក ដែលអាចប្រមើលឃើញ។ ដូច្នេះ ការលើកឡើងបែបសោកស្តាយរបស់ អ.ប.ជ ដែលថា នៅក្នុងប្រវត្តិនៃយុត្តិធម៌ព្រហ្មទណ្ឌជាតិ និងអន្តរជាតិ មិនដែលធ្លាប់មានការចេញសេចក្តីសម្រេចផ្ទុយគ្នាចំនួនពីរ ដែលចេញដោយការិយាល័យចៅក្រមតែមួយ[56] គឺជាការភាន់ច្រឡំយ៉ាងច្បាស់ក្រឡែត និងអាចត្រូវបានសំដៅប្រឆាំងនឹងខ្លួនឯង ដូចដែល អ.ជ.ត.ក បានសម្រេចជាធរមាន។

២៧. ហេតុដូច្នេះ សំណុំរឿងចាំបាច់ ត្រូវតែចេញផុតពីការជាប់គាំង ដោយត្រូវចងចាំផងដែរថា ការលើកលែងទោសដោយព្រះមហាក្សត្រ ដែលអាចជាលទ្ធភាពនៃដំណោះស្រាយដែលសមហេតុផលនោះ ក៏ត្រូវបានហាមឃាត់តាមមាត្រា ១(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ៤០ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

## **ខ. អង្គសេចក្តី**

### ***១. ការបញ្ជូន[57] សំណុំរឿង***

២៨. សំណើសុំមិនមានមូលដ្ឋានសមស្រប។

២៩. បញ្ហាថាតើ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ហើយអាចត្រូវបានបញ្ជូន ឬយ៉ាងណានោះ គឺជាអង្គសេចក្តីមួយក្នុងចំណោមអង្គសេចក្តីនានានៃសំណើសុំ មិនមែនភាពអាចទទួលយកបាននៃដីកានេះទេ។

---

[56] សេចក្តីពិចារណា ក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ១០៩។

[57] ពួកយើងមានបញ្ហាខ្លះៗ ជាមួយពាក្យពេចន៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិដែលថា ពួកយើងមាន "ភារកិច្ច" បញ្ជូនសំណុំរឿង "ដើម្បីធានាបាននូវការអនុវត្តតាម "គោលការណ៍រួមដែលថា កិច្ចដំណើរការនីតិវិធី អ.វ.ត.ក ចាំបាច់ត្រូវគោរពតាមលក្ខខណ្ឌតម្រូវ នៃនីត្យានុកូលភាព ភាពត្រឹមត្រូវយុត្តិធម៌ និងប្រសិទ្ធភាព តាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក" ដើម្បីសម្រេចបាន "យុត្តិធម៌ព្រហ្មទណ្ឌប្រកបដោយប្រសិទ្ធភាព" សំណើ នៅត្រង់ កថាខណ្ឌ ២ និង១៥។ ការនេះហាក់ដូចជាការបកស្រាយតែម្ខាង ទៅលើពាក្យ "យុត្តិធម៌" ដែលស្ថិតនៅក្នុងវាក្យសព្ទបច្ចេកទេសនេះ។

៣០. ទស្សនៈរបស់ ស.ព.អ ដែលផ្អែកលើមតិយោបល់របស់ចៅក្រមអន្តរជាតិនៃ អ.ប.ជ អំពីអត្ថិភាពនៃការសម្រេចជាឯកច្ឆន្ទ ដោយចៅក្រមទាំងប្រាំរូប ថាដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានសុពលភាពនោះ គឺធ្វើឲ្យពាក្យពេចន៍របស់ ចៅក្រមជាតិស្ថិតក្រៅបរិបទ ទាំងនៅក្នុងសេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ និងទាំងប្រៀបធៀបជាមួយ សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ ដែលត្រូវបានចេញសឹងតែភ្លាមៗ បន្ទាប់ពីសវនាការក្នុងសំណុំរឿង ០០៣។

៣១. នៅក្នុងសំណុំរឿងទាំងពីរ ចៅក្រមជាតិដដែល ដែលនាពេលកន្លងមក និងនៅទូទាំងដំណាក់កាលស៊ើបអង្កេតទាំងអស់ បានបដិសេធជារឿយៗនូវអត្ថិភាពនៃយុត្តាធិការបុគ្គលនោះ បានបង្ហាញយ៉ាងច្បាស់នូវទស្សនរបស់ខ្លួន នៅក្នុងសេចក្តីពិចារណាទាំងពីរថា ពួកគេ *មិន*ចង់ឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ បន្តទៅជំនុំជម្រះឡើយ។ ស្ថានភាពក្នុងសំណុំរឿងនេះ តាមពិតទៅគឺមិនខុសគ្នាពីស្ថានភាព នៅក្នុងសំណុំរឿង ០០៤/២ ឡើយ។

៣២. សេចក្តីសន្និដ្ឋានរបស់យើង ទាញចេញពីសម្មតិកម្មចំនួនពីរសាមញ្ញ គឺ៖ ទីមួយ គឺចេញពីគោលការណ៍ដែលថា សំណុំរឿងដូចគ្នា ចាំបាច់ត្រូវអនុវត្តដូចគ្នា។ សំណុំរឿង ០០៤/២ និងសំណុំរឿង ០០៣ គឺដូចគ្នាទាំងស្រុង លើបញ្ហាសំខាន់ៗនៃយុត្តាធិការបុគ្គល និងបញ្ហានៃដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា។

៣៣. ទីពីរ ការសន្មតគឺថា ចៅក្រមតែមួយ នឹងធ្វើការសម្រេចទៅលើបញ្ហាគតិយុត្តិដូចគ្នា នៅក្នុងលក្ខណៈដូចគ្នា លើកលែងតែ ក.) ទស្សនៈរបស់ពួកគេ បានផ្លាស់ប្តូរ ហើយពួកគេបានបញ្ជាក់យ៉ាងច្បាស់ថា ពួកគេចង់ងាកចេញពីការយល់ឃើញកន្លងមករបស់ខ្លួន ឬ ខ.) ថាច្បាប់បានផ្លាស់ប្តូរ ហើយច្បាប់ថ្មីតម្រូវឲ្យមានលទ្ធផលផ្សេងគ្នា។ ស្ថានភាពបែបនេះមិនមានឡើយក្នុងករណីនេះ។ វាហាក់ដូចជាការអះអាងដែលទាល់ច្រកយ៉ាងពិសេស ក្នុងការនិយាយសំដៅថា ចៅក្រមជាតិបានផ្លាស់ប្តូរទស្សនៈរបស់ខ្លួន សម្រាប់សំណុំរឿង ០០៣ បន្ទាប់ពីស្តាប់ទឡ្ហីករណ៍ក្នុងសំណុំរឿង ០០៣ ដែលពួកគេអាច និងគួរតែបានធ្វើការពិចារណារួចទៅហើយ ក្នុងសំណុំរឿង០០៤/២។

៣៤. ពួកយើងមិនបាច់ព្យាយាមបកស្រាយ នូវសំអាងហេតុដែលធ្វើឲ្យចៅក្រមជាតិ បែរជាប្រើប្រាស់វិធីសាស្ត្រ និងពាក្យពេចន៍ផ្សេង នៅក្នុងសំណុំរឿង ០០៣ និងបកស្រាយថា តើចេតនាពិតប្រាកដ របស់ពួកគេគឺជាអ្វីនោះដែរ។ ប៉ុន្តែពួកយើងជឿជាក់ទាំងស្រុងថា ការនិយាយថាដីកាដំណោះស្រាយទាំងពីរមានសុពលភាព ពិតជាមិនមែនមានន័យថា យល់ព្រមឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបញ្ជូនទៅអង្គជំនុំ

ជម្រះសាលាដំបូងឡើយ ព្រោះពួកគាត់ខ្លួនឯងបានបង្គាប់ឲ្យដាក់សំណុំរឿងចូលទៅក្នុងបណ្ណសារ។ អ្វីផ្សេងទៀតទាំងអស់ គឺជាការបំភាន់។

៣៥. ទាំងភាពជាឯកច្ឆន្ទ ក៏ដូចជាសម្លេងភាគច្រើនលើសលប់ គឺមិនមានឡើយនៅក្នុងចំណោមចៅក្រមអង្គបុរេជំនុំជម្រះ សម្រាប់ដីកាដំណោះស្រាយណាមួយ នៅក្នុងសំណុំរឿង ០០៣។ ជាថ្មីម្តងទៀត វិធានរកសំឡេងមិនបាន គឺមិនត្រូវបានគោរពតាម ដោយចៅក្រមទាំងអស់ដដែល ដែលបានប្រកាសពីការសម្រេចនេះ ដែលការនេះបង្ករឲ្យមានការមន្ទិលយ៉ាងខ្លាំង ទៅលើការទទួលយកជាឯកច្ឆន្ទជាក់ស្តែង ដោយចៅក្រមអង្គបុរេជំនុំជម្រះទាំងអស់ ទាំងលើអត្ថន័យ និងលើអានុភាពចងកាតព្វកិច្ចរបស់វា។ ទោះជាបែបណាក្តី អង្គជំនុំជម្រះសាលាដំបូង មិនទាន់បានទទួលសំណុំរឿងឡើយ។ ពួកយើងយល់ស្របជាមួយគ្នាទាំងស្រុងថា ពួកយើងមិនអាចបញ្ជូនសំណុំរឿង និងដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅកាន់ អ.ជ.ស.ដ ដោយផ្អែកលើមូលដ្ឋាននោះបានឡើយ។

៣៦. សហចៅក្រមស៊ើបអង្កេតជាតិ សូមបន្ថែមថា ប្រាកដណាស់ ដោយសារតែមិនមានការគោរពតាមដោយចៅក្រមជាតិ ទៅលើ វិធានរកសំឡេងមិនបាន សហចៅក្រមស៊ើបអង្កេតជាតិ មិនចាត់ទុកថាខ្លួនជាប់កាតព្វកិច្ចដោយសេចក្តីសម្រេចនោះឡើយ ហើយនៅបន្តរក្សាទស្សនៈរបស់ខ្លួនដដែលទៅលើយុត្តាធិការបុគ្គលក្នុងសំណុំរឿងនេះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កត់សម្គាល់អំពីទស្សនៈនេះ និងផលវិបាកនៃទស្សនៈនេះ សម្រាប់តែប្រភេទនៃដីកាដំណោះស្រាយរួម ដែលនៅតែអាចមាន សម្រាប់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដូចជាការបិទបញ្ចប់សំណុំរឿង ដោយផ្អែកលើមូលដ្ឋាននៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដូចបានលើកឡើងពីខាងលើ ឬជាជម្រើសផ្សេងទៀត ដោយសារតែមិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានសុពលភាព ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចនៅក្នុងសំណុំរឿង ០០៤/២។

៣៧. នៅក្នុងបរិបទនេះ គ្មាននរណាម្នាក់ក្នុងចំណោមពួកយើងទាំងពីរ នឹងបញ្ជូនសំណុំរឿងតែឯកឯងឡើយ។ "ដំណោះស្រាយ" នេះ ដូចដែលបានស្នើឡើងដោយចៅក្រមអន្តរជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ជាខ្លឹមសារ គឺមិនខុសពីការមានដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នាជាថ្មីនោះឡើយ។ គឺដូចគ្នាថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង ហើយសហចៅក្រមស៊ើបអង្កេតជាតិ អាចបង្គាប់ឲ្យបោះត្រា និងដាក់សំណុំរឿងទៅក្នុងបណ្ណាសារ អង្គបុរេជំនុំជម្រះក៏នឹងមិនអាចសម្រេច សម្រាប់ករណីទាំងពីរ ឬ អត់តែម្តង។

### ២. ការណែនាំរដ្ឋបាល

៣៨. ជារួម ដោយសារតែសេចក្តីសម្រេច លែងពឹងផ្អែកលើបញ្ហានេះហើយ ពួកយើងក៏ជឿជាក់ទាំងស្រុងថា អង្គបុរេជំនុំជម្រះនៅតែអាចចេញសេចក្តីណែនាំរដ្ឋបាល អំពីជោគវាសនារបស់សំណុំរឿង ដោយខ្លួនឯងបាន ដូចដែលបានបង្ហាញស្រាប់ហើយ តាមរយៈការពិតដែលថា ចៅក្រមជាតិសម្រេចជ្រើសរើសការអនុវត្តបែបនេះ នៅក្នុងសំណុំរឿងនេះ និងតាមការចេញភ្លាមៗនូវអនុស្សរណៈពាក់ព័ន្ធ ពីអង្គបុរេជំនុំជម្រះ ផ្ញើរជូនទៅការិយាល័យរដ្ឋបាល នៅក្នុងសំណុំរឿង ០០៤/២។ បើទោះបីជានៅក្នុងសេចក្តីពិចារណានៅក្នុងសំណុំរឿង ០០៣ ចៅក្រមអន្តរជាតិបានបញ្ជាក់ថា ភ្លាមៗបន្ទាប់ពីចេញដីកាដំណោះស្រាយ ការិយាល័យសហចៅក្រមស៊ើបអង្កេត លែងមានអាណត្តិការងារទៀតក្តី លើកលែងតែ "មុខងាររដ្ឋបាល" នោះ[58] ចៅក្រមប្រធានអង្គបុរេជំនុំជម្រះ ព្រមទាំងចៅក្រមអន្តរជាតិខ្លួនឯងផ្ទាល់ នាពេលកន្លងមកបានចេញសេចក្តីណែនាំផ្ទុយគ្នា តាមរយៈក្រឡាបញ្ជីរបស់ខ្លួន ទៅអង្គភាពបណ្ណាសាររបស់ ការិយាល័យរដ្ឋបាល ឲ្យដាក់សំណុំរឿង ០០៤/២ ចូលក្នុងបណ្ណាសារ ឬបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង[59]។ ពួកគាត់នឹងមិនអនុវត្តបែបនេះទេ ប្រសិនបើពួកគាត់គិតថា មានតែពួកយើងប៉ុណ្ណោះដែលអាចធ្វើបាននោះ។

៣៩. ដូច្នេះ ការបញ្ជូនបញ្ហាមកពួកយើងនាពេលនេះ ដើម្បីជាដំណោះស្រាយ "រដ្ឋបាល" ទៅលើការជាប់គាំងនៅចំពោះមុខការមិនអាចសម្រេចបានជាបន្តបន្ទាប់របស់អង្គបុរេជំនុំជម្រះខ្លួនឯងនោះ គឺហាក់ដូចជាមានលក្ខណៈវៀចវេរមិនទៀងត្រង់សោះ។

---

[58] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ មតិរបស់ចៅក្រម Olivier Beauvallet និងចៅក្រម Kang Jin Baik កថាខណ្ឌ ១៣២។

[59] **សំណុំរឿងលេខ ០០៤/២ ឯកសារ D359/34** & **D360/44** *អនុស្សរណៈរបស់ចៅក្រមប្រធាន ពាក់ព័ន្ធការជូនដំណឹង អំពីសេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២* ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០។ **សំណុំរឿងលេខ ០០៤/២ ឯកសារ D359/35** & **D360/44** *អនុស្សរណៈរបស់ចៅក្រមអន្តរជាតិ នៃអង្គបុរេជំនុំជម្រះ ពាក់ព័ន្ធការជូនដំណឹងអំពី សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២* ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០។ **សំណុំរឿងលេខ ០០៤/២ ឯកសារ D359/36** & **D360/45** *អនុស្សរណៈរបស់ចៅក្រមអន្តរជាតិ ពាក់ព័ន្ធការបញ្ជូនសំណុំរឿង ០០៤/២* ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។ **សំណុំរឿងលេខ ០០៤/២ ឯកសារ D359/37** & **D360/46***អនុស្សរណៈរបស់ចៅក្រមប្រធាន ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០* ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។

### *៣. ការសម្រេចសេចក្ដីស្ថាពរលើសំណុំរឿង*

៤០. ច្បាស់ណាស់ថា ពួកយើងបច្ចុប្បន្ន មិនមានយុត្តាធិការក្នុងការសម្រេចលើជោគវាសនានៃសំណុំរឿង ០០៣ ឡើយ ដោយសារតែសំណុំរឿង ស្ថិតក្នុងការរង់ចាំការសម្រេចរបស់អង្គបុរេជំនុំជម្រះ សម្រាប់បញ្ហាភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងសំណើសុំពន្យារពេលតាមវិធាន ៨០(១) នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ជូនទៅអង្គជំនុំជម្រះសាលាដំបូង ហើយការបដិសេធពីអង្គជំនុំជម្រះសាលាដំបូង ប្រហែលជាចុងក្រោយនឹងបើកផ្លូវទៅដល់ការសម្រេចមួយផ្សេងទៀតរបស់អង្គជំនុំជម្រះតុលាការកំពូល ដូចនៅក្នុងសំណុំរឿង ០០៤/២ ដែរ។

៤១. ប៉ុន្តែ ពួកយើងមិនឃើញមានហេតុផលណាមួយ ដែលត្រូវរង់ចាំសេចក្ដីសម្រេចរបស់យើង លើបញ្ហានៅចំពោះមុខឡើយ ដូចដែលពួកយើងបានអនុវត្តក្នុងសំណុំរឿង ០០៤/២ ដែរ។ សំណើសុំគឺដល់ពេលវេលាហើយ សម្រាប់ការសម្រេច ដែលតាមពិតទៅ ការសម្រេចអាចជួយជម្រុញដល់ដំណោះស្រាយសម្រាប់ជោគវាសនារបស់សំណុំរឿងផង។

៤២. ទោះជាបែបនេះក្ដី ពួកយើងចង់ផ្ដល់យោបល់ដល់ភាគីនានាថា ប្រសិនបើមិនមានមធ្យោបាយណាផ្សេង ដើម្បីជម្រុញដល់សំណុំរឿងនេះ ឲ្យទៅជំនុំជម្រះ ឬទៅដល់ការបិទបញ្ចប់ ដូចក្នុងសំណុំរឿង ០០៤/២ ទេ ហើយប្រសិនបើមិនមានស្ថាប័នតុលាការដទៃណា នៅក្នុងតុលាការនេះ មានចេតនាក្នុងការទទួលយកមកអនុវត្តដោយខ្លួនឯង នូវមធ្យោបាយណាមួយនោះ ជាជម្រើសចុងក្រោយបំផុត (*ultima ratio*) និងបន្ទាប់ពីដំណើរការអស់នូវយុត្តាធិការទាំងឡាយដែលមាន ពួកយើងនឹងបើកឱកាសទទួលយកឬស្នើសុំនូវទឡ្ហីករណ៍នានាអំពីបញ្ហាថា តើពួកយើងមានយុត្តាធិការដែលនៅសេសសល់ពិសេសណាមួយដែលជាមធ្យោបាយចុងក្រោយបំផុត ក្នុងការបិទបញ្ចប់សំណុំរឿងដោយខ្លួនឯង ដើម្បីផ្ដល់ប្រសិទ្ធភាពដល់គោលការណ៍ទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលមានកម្រិតខ្ពស់ជាង ក្នុងការសម្រេចសេចក្ដីទៅលើសំណុំរឿងឲ្យបានត្រឹមត្រូវ និងដើម្បីការពារសិទ្ធិរបស់ មាស មុត ក្នុងការទទួលបាននូវការសម្រេចជាស្ថាពរទៅលើសំណុំរឿងប្រឆាំងនឹងខ្លួនឲ្យបានឆាប់រហ័ស។ យើងពិតជាមិនចង់ស្ថិតក្នុងស្ថានភាពបែបនោះឡើយ ប៉ុន្តែយើងចាត់ទុកថាជាការចាំបាច់ ដើម្បីសង្កត់ធ្ងន់ថា នីតិរដ្ឋពិតជាមានតម្លៃ ហើយសំណុំរឿងត្រូវតែចេញផុតពីការជាប់គាំង។

៤៣. ពួកយើងដឹងថា នេះគឺជាចំណាត់ការខុសប្រក្រតី ប៉ុន្តែយើងក៏សូមជំរុញឱ្យសហព្រះរាជអាជ្ញាអន្តរជាតិ ប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចនេះ ទៅអង្គបុរេជំនុំជម្រះ ដើម្បីឱ្យអង្គបុរេជំនុំជម្រះធ្វើការពិចារណាឡើងវិញ ឬយ៉ាងហោចណាស់បញ្ជាក់បំភ្លឺ ទៅលើទស្សនៈរបស់ខ្លួនលើខ្លឹមសារ ការទទួលយកជាឯកច្ឆន្ទដោយចៅក្រមទាំងអស់នៃ អ.ប.ជ និងអានុភាពចងកាតព្វកិច្ច តាមវិធានរកសំឡេងមិនបាន ភាពធ្ងន់ធ្ងរនៃការរំលោភបំពានលើវា អានុភាពនៃការមិនអនុវត្តតាម លើបញ្ហានៃការជំនុំជម្រះប្រកបដោយយុត្តិធម៌នៃសំណុំរឿងនេះ និងនាំទៅដល់ការបញ្ចប់សំណុំរឿងនេះឱ្យបានត្រឹមត្រូវ តាមសិទ្ធិអំណាចដែលអង្គបុរេជំនុំជម្រះ បានប្រកាសថាខ្លួនមាននោះ។

**ផ្អែកលើសំអាងហេតុដូចបានរៀបរាប់ខាងលើ យើង[60]សម្រេច បដិសេធសំណើនេះ៕**

ភ្នំពេញ ថ្ងៃទី **២០** ខែ**ឧសភា** ឆ្នាំ **២០២១**

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**

**Co-juges d'instruction**

**យូ ប៊ុនឡេង** Michael Bohlander

[60] ទោះបីជាសហចៅក្រមស៊ើបអង្កេត ចេញសេចក្តីសម្រេចនេះរួមគ្នាក្តី តែជាកំណត់ត្រា សហចៅក្រមស៊ើបអង្កេតជាតិ កត់សម្គាល់ថា ឯកសារដែលត្រូវដាក់ចូលទៅក្នុងសំណុំរឿង ត្រូវដាក់លេខតាមលំដាប់ បន្ទាប់ពីឯកសារចុងក្រោយ ដែលបានដាក់នៅមុនពេលការលាលែងពីតំណែងរបស់ចៅក្រម Siegfried Blunk ដោយមិនបញ្ចូលដីកាសម្រេច និងសេចក្តីសម្រេចនានា ដែលចេញដោយសហចៅក្រមស៊ើបអង្កេតបម្រុង Laurent Kasper-Ansermet ឡើយ។